# ជំពូក ៣

# អំពីបុព្វប្រវត្តិសាស្ត្រខ្មែរ

## ក. ប្រវត្តិទឹកដីខ្មែរ

ការសិក្សាពីបុព្វប្រវត្តិសាស្ត្រខ្មែរ តម្រូវអោយយើងដឹងពីអាយុកាលនៃទឹកដីខ្មែរផងដែរ ដែលមានប្រវត្តិជាប់ទាក់ទងនឹងអាស៊ីអាគ្នេយ៍ទាំងមូល ។ យ៉ាងណាមិញគេបានដឹងថា នៅដើមនិងចុងស័ក (ère) ទី១ ភូមិភាគអាស៊ីអាគ្នេយ៍បានពើបប្រទះនឹងពើងផ្នត់កាឡេដូន្យាង (Plissement calédonien) និងពើងផ្នត់អែរស៊ីន្យាង (Plissememt hercynien) ដែលបណ្តាលអោយផុះផុលកើតបានជាជួរភ្នំនិងខ្ពង់រាបនានានៅពាសពេញប្រទេសខ្មែរសព្វថ្ងៃ ។ បន្ទាប់មកដីដែលផុះផុសឡើងនេះក៏ត្រូវទឹកសមុទ្រទន្ទ្រានបណ្តាលអោយលិចលង់អស់រហូតដល់ដំណាច់ស័កទី ៣ ។ នៅដើមស័កទី៤មានការបំផុសដីម្តងទៀតចាប់ពីភូមិភាគភ្នំហេមពាន្ត ចុះរហូតដល់ភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល ។ ដីខ្មែរត្រង់ភាគខ្លះក៏ផុះឡើងកំពស់ពី៧០០ទៅ៨៨០ម៉ែត្រ ។ ក្នុងអំឡុងស័កទី៤នេះ គេសង្កេតឃើញមានលំនាច និងជំនោរទឹកសមុទ្រ ឆ្លាស់គ្នាច្រើនលើកច្រើនសា ជាហេតុបណ្តាលអោយដីដែលផុះឡើងហើយត្រូវលិចបាត់ទៅក្នុងទឹកសមុទ្រវិញ រួចផុះឡើងសាជាថ្មីម្តងទៀត ។នៅចន្លោះពី៦០០០០០ដល់១៥០០០ឆ្នាំមុនគ. ស. ទឹកសមុទ្របាននាចថយទៅពី១៣០ដល់១៨០ម៉ែត្រ (បើប្រៀបនឹងកំពស់ទឹកសមុទ្រសព្វថ្ងៃ) ។ ភូគព្ភវិទូខ្លះបានពន្យល់ថា ដោយអាស្រ័យហេតុខាងលើនេះហើយបានជាកាលណោះភូមិភាគឥណ្ឌូចិន និងប្រជុំកោះអាំងស៊ុយឡាំង(Insulinde ) ស្ថិតជាប់គ្នារហូតគ្មានសមុទ្រខណ្ឌ ដូចយើងឃើញសព្វថ្ងៃនេះទេ ។ នៅប្រមាណ១៥ ០០០ឆ្នាំមុនគ. ស. ទឹកសមុទ្របានជោរឡើងកំពស់១៥ម. ដែលជាហេតុនាំអោយទឹកដីខ្មែរក្រោមព្រមទាំងវាលទំនាបប្រទេសខ្មែរបច្ចុប្បន្នខ្លះលិចបាត់ទៅក្នុងទឹកវិញ ។នៅស. វ. ទី៣មុនគ. ស. ទឹកសមុទ្របាននាចបន្តិចម្តងៗទៅវិញ ។ ឯទន្លេមេគង្គក៏បាននាំដីល្បាប់មកចាក់បង្កើតជាដីសណ្តរចុះទៅទិសខាងត្បូង ដេញតាមសម្រកទឹកសមុទ្របន្តិចម្តងៗដែរ(៥) ។

## ខ. បុព្វប្រវត្តិសាស្ត្រខ្មែរ

តើទឹកដីខ្មែរដែលមានប្រវត្តិដូចបានរៀបរាប់ខាងលើនេះ មានមនុស្សមករស់នៅចាប់តាំងពីពេលណាមក ? ហើយការរស់នៅក្នុងសម័យដើមនោះមានលក្ខណៈដូចម្ដេចខ្លះ ?

### ១. ស្ថានីយបុព្វប្រវត្តិសាស្ត្រ

ចំពោះបញ្ហានេះបុព្វប្រវត្តិវិទូបានពោលថា បុព្វប្រវត្តិសាស្ត្រខ្មែរ មិនទាន់មានលក្ខណៈច្បាស់លាស់ ព្រោះការស្រាវជ្រាវក្នុងវិស័យនេះមិនទាន់បានធ្វើអោយជិតដល់នៅឡើយ ។ ចំពោះយុគថ្មបំបែក គេទើបតែរកឃើញដានខ្លះៗប៉ុណ្ណោះ ។ នៅឆ្នាំ១៩៦៣លោក E.Saurin បានរកឃើញដុំថ្មថាំងនៅក្នុងទន្លេមេគង្គ នៅចន្លោះខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ ។ ក្រៅពីនេះនៅ មានវត្ថុផ្សេងទៀតធ្វើពីថ្មថាំងត្រូវបានគេរកឃើញនៅតំបន់អង្គរដែរ ។ ស្ថានីយឯទៀតៗ ដែលគេបានរកឃើញរហូតដល់សព្វថ្ងៃមានចំនួន៦ ហើយសុទ្ធតែជាស្ថានីយទាក់ទងនឹងយុគថ្មរំលីងលាយលោហធាតុ ។

#### ១.១ ស្ថានីយ សំរោងសែន - អន្លង់ផ្ដៅ - ម្លូព្រៃ

សំរោងសែនជាស្ថានីយមួយស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ខាងជើងបឹងទន្លេសាប ។ ស្ថានីយនេះជាដីទួលមួយមានកំពស់៥ម៉ែត្រហើយមានផ្ទៃប្រមាណ៦០០០ម៉ែត្រក្រឡាប៉ុណ្ណោះ ។ លោក Roques បានរកឃើញស្ថានីយនេះនៅឆ្នាំ១៨៧៦ ឯលោក Corre បានបោះពុម្ពផ្សាយពីរបស់ដែលគេរកឃើញនៅទីនោះ នៅឆ្នាំ១៨៧៩ ។ ក្រោយមក លោកMoura (១៨៨២)លោកAymonier (១៩០១)លោកMansuy (១៩០២និង១៩២៣)បានទៅធ្វើការរុករកនៅទីនោះទៀត ។ ការរកឃើញស្ថានីយនេះនៅឆ្នាំ១៨៧៦ ជាជំហានដំបូងក្នុងការស្រាវជ្រាវផ្នែកបុព្វប្រវត្តិសាស្ត្រនៅអាស៊ីអាគ្នេយ៍ ។

អន្លង់ផ្ដៅជាស្ថានីយមួយស្ថិតនៅចំងាយ ៣០គ.ម.ត្រង់ទិសអាគ្នេយ៍ពីសំរោងសែន ហើយមានប្រដាប់ប្រដាដូចនៅស្ថានីយខាងលើនេះដែរ ។ លោក Mansuy បានរកឃើញស្ថានីយនេះនៅឆ្នាំ១៩០២ ហើយបានដាក់ឈ្មោះហៅថា Longprao ទៀតផង ។ ម្លូព្រៃស្ថិតនៅខាងជើងខេត្តព្រះវិហារហើយត្រូវបានរកឃើញដោយលោក P.lé vy នៅឆ្នាំ១៩៤៣ ។ ស្ថានីយនេះថ្មីជាងស្ថានីយពីរខាងលើព្រោះមានប្រដាប់ប្រដាធ្វើពីលោហធាតុច្រើន ។ វត្ថុដែលគេបានរកឃើញនៅស្ថានីយទាំង៣នេះមាន :

- **ពីថ្មរំលីង :** ពូថៅដែលមានពន្លួញ ពន្លាក ញញួរ ត្បោងដំសំបកឈើយកសរសៃ ទ្រនាប់កាំបិទ កណ្ដៀវ ថ្មសំលៀង ពុម្ពចាក់កណ្ដៀវ កងដៃ ក្បាលត្រល់ អង្រែ ផ្លែសន្ទូច
- **ពីឆ្អឹងសត្វ:** ចុងព្រួញ កាំបិត ផ្លែសន្ទូច កណ្ដៀវ គ្រឿងអលង្ការ

- **ពីសំបកខ្យង:** អង្កាំ ទំហូ
- **ពីដីឥដ្ឋ :** ទំហូ អង្កាំ ក្អម ឆ្នាំង ចានទាប ចានក្រឡូម ចានជើង
- **ពីលង្ហិន :** ចុងព្រួញ កណ្តៀវ ពូថៅ ដួង ផ្លែសន្ទូច
- **ពីដែក :** មានតែពន្លាក១គត់នៅស្ថានីយម្លូព្រៃ ។
- **ឆ្អឹងមនុស្ស :** ឆ្អឹងស្មង ឆ្អឹងភ្លៅ ឆ្អឹងដើមដៃ លលាដ៍ក្បាល១
- **សំណល់ផ្ទះបាយ :** ធ្យូង ។



*ពូពូថៅថ្មរំលីងមានពន្លួញ*



*ចានជើងធ្វើពីដីឥដ្ឋ*



*ផ្លែសន្ទូចធ្វើពីលង្ហិន*

ក្នុងចំណោមរបស់ទាំងឡាយដែលបានរៀបរាប់ពីខាងលើ យើងបានសង្កេតឃើញថា វត្ថុធ្វើពីថ្មរំលីងបាននៅលាយឡំជាមួយនឹងវត្ថុធ្វើពីលោហធាតុ ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា នៅប្រទេសខ្មែរយើងពុំមានព្រំដែនអោយច្បាស់លាស់រវាងយុគថ្ម និងយុគលោហៈទេ ។ ឯរបស់ដែលធ្វើពីដែក មានតែមួយគត់គឺ ពន្លាកនៅម្លូព្រៃ : ត្រង់នេះសអោយឃើញថាមនុស្សបុព្វប្រវត្តិសាស្ត្រប្រហែលជាមិនទាន់ចេះស្លដែកនៅឡើយទេ ហើយបានរៀនបច្ចេកទេសនេះពីពួកឥណ្ឌា ព្រោះគេបានសង្កេតឃើញថាពួកកួយដែលចេះស្លដែកនៅក្នុងខេត្រកំពង់ធំ នៅប្រើប្រាស់ស្នប់ ដែលគេឃើញមានប្រើប្រាស់ក្នុងរដ្ឋឧរិស្សរបស់ឥណ្ឌានៅឡើយ ។ ម្យ៉ាងទៀត ពិធីសែនព្រេន ដែលពួកកួយប្រារព្ធធ្វើមុនពេលស្លដែកម្តងៗ ក៏ជាពិធីខាងសាសនាព្រាហ្មណ៍ដែរ ។

គួរបញ្ជាក់ថានៅឆ្នាំ១៩០១ គេបានរកឃើញនៅកោះសំរោងសែននូវលលាដ៍ក្បាល១ ដែលពុកផុយច្រើនណាស់ទៅហើយដោយសារតែទឹកជំនន់នៅទីនោះ ។ ក្រោយពីបានសិក្សា ពួកបុព្វប្រវត្តិវិទូ

បានចាត់ទុកថាឆ្អឹងលលាដ៍នេះស្ថិតនៅចន្លោះពួកក្បាលកណ្ដាល ( mésocéphalie) គឺពពួកក្បាលមូល (Sons- brachycéphalie ) ។ បើដូច្នេះយើងឃើញថាចំណាត់ខាងលើនេះមានលក្ខណៈស្របនឹងលទ្ធផលរបស់លោក J. Deriker ដែលលោកបានរកឃើញថាជនជាតិខ្មែរបច្ចុប្បន្ននេះជាពូជដែលមានក្បាលមូល ( Sous - brachycéphalie ) ដោយមានសន្ទស្សន៍លលាដ៍ ៨៣,៦... ។ ការប្រៀបធៀបនេះបានអនុញ្ញាតអោយយើងសន្និដ្ឋានបានថា មនុស្សដែលរស់នៅសម័យសំរោងសែនគឺពិតជាបុព្វបុរស របស់ជនជាតិខ្មែរសព្វថ្ងៃ ហើយលោកមិនទាន់បានទទួលឥទ្ធិពលឥណ្ឌានៅឡើយក្នុងវិស័យបូជាសព ។

ដោយសំអាងទៅលើកំពស់ដីល្បប់(៥ម.) ដែលគ្របពីលើស្ថានីយសំរោងសែន អ្នកបច្ចេកទេសបានសន្និដ្ឋានថា ស្ថានីយនេះមានអាយុប្រហែល១០០ឬ២០០ឆ្នាំមុន គ.ស. ។

## ១.២ ស្ថានីយព្រៃកន្លង

នេះជាស្ថានីយថ្មរំលីងមួយទៀតដែលលោកB.P.Groslier បានរកឃើញនៅព្រៃកន្លង (ស្រុកមេមត់ខេត្តកំពង់ចាម)នៅឆ្នាំ១៩៦២(10) ។

ជាយូរមកហើយលោក Groslier បានសិក្សាពីលើយន្តហោះនូវស្នាដៃធ្វើពីដីមានរាងមូល ដែលនៅរាយប៉ាយ ចាប់តាំងពីឡាបានសៀកដល់ឡុកនិញ (LocNinh) ក្នុងប្រទេសវៀតណាមខាងត្បូងដោយឆ្លងកាត់តាមមេមត់ បានសេចក្ដីថាស្នាដៃទាំងនោះស្ថិតនៅក្នុងតំបន់ដីក្រហមនៃចំការកៅស៊ូធំៗ ។

មានសញ្ញានិងសម្មតិកម្មជាច្រើនបានស្របគ្នា ជាហេតុនាំអោយលោក Groslier ជឿថាទីកន្លែងទាំងនោះជាទីលំនៅ របស់ជនជាតិខ្មែរដើម ។ ដូច្នេះ ដើម្បីធ្វើការបញ្ជាក់ពីគំនិតនេះ នៅឆ្នាំ១៩៦២ លោក Groslier បានជ្រើសរើសយកទីកន្លែងមួយនៅព្រៃកន្លង ដើម្បីធ្វើកំណាយព្រោះកន្លែងនោះស្ថិតនៅចំកណ្ដាលប្រព័ន្ធទាំងមូល ។ ក្នុងការរុករកនេះលោក Groslier បានរកឃើញរបស់ធ្វើពីថ្មនិងគ្រឿងចានឆ្នាំងមួយចំនួនធំ ។ វត្ថុទាំងនោះបានបង្ហាញអោយឃើញថានៅត្រង់កន្លែងដែលជាជំរំការពារយ៉ាងមាំមួននោះមានមនុស្សរស់នៅដោយមានការរៀបចំយ៉ាងហ្មត់ចត់ហើយ ។ ជំរំដែលលោក Groslier បានសិក្សា មានកំពែងរាងមូលព័ទ្ធជុំវិញ (វិជ្ឈមាត្រជាង២០០ម.)ហើយមានផ្លូវចូលពីរ ។ អាយុនៃជំរំមានប្រហែលពី១៥០០ដល់៥០០ឆ្នាំមុនគ.ស. ។ ប្រដាប់ប្រដាដែលធ្វើពីថ្មរំលីងមានរាងប្លែកៗខ្លះមានរាជាពង ខ្លះមានរាងជាចតុមុម យកលំនាំតាមរបស់ដែលធ្វើពីលង្ហិនដំបូង ។ គ្រឿងចានឆ្នាំងមានរាងច្រើនបែបយ៉ាង ហើយមានក្បាច់រចនាល្អវិចិត្រ ប៉ុន្តែក្រោយមកបែរជាមានសភាពគ្រោតគ្រាតគ្មានលំអអ្វីសោះ ។ វត្ថុទាំងអស់នេះគេចាត់ទុកថាជាស្នាដៃរបស់ជនជាតិខ្មែរដើម មុនពេលដែលជនជាតិនេះចុះមករស់នៅត្រង់វាលទំនាបនៃទន្លេមេគង្គ និងមុនពេលដែលបានទទួលអរិយធម៌ឥណ្ឌា ។

## ១.៣ ស្ថានីយល្អាងស្ពាន

ពីឆ្នាំ ១៩៦៦ដល់ឆ្នាំ១៩៦៩ លោកនិងលោកស្រី Mourer សាស្ត្រាចារ្យនៅមហាវិទ្យាល័យបុរាណវត្ថុវិទ្យា ដោយមាននិស្សិតនៃមហាវិទ្យាល័យនេះចូលរួមផង បានធ្វើកំណាយនៅរូងភ្នំល្អាងស្ពាននៃភ្នំទាកទ្រាំង មានចម្ងាយប្រមាណ៥គ.ម.ពីអណ្ដើកហែបខែត្របាត់ដំបង(11) ។ វត្ថុដែលគេបានរកឃើញមានចំនួនប្រមាណជា២០០០ហើយមានជាអាទិ គ្រឿងប្រដាប់ធ្វើពីថ្ម សំណល់ផ្ទះបាយ សាកសពសត្វល្អិត បំណែកគ្រឿងថានឆ្នាំង ឆ្អឹងសត្វ(Rhinoceros Sondaicusm Desm) និងឆ្អឹងមនុស្ស(ឆ្អឹងដើមដៃនិងឆ្អឹងជងកាំបិត) ។ វត្ថុទាំងនេះត្រូវបានគេផ្ញើទៅប្រទេសបារាំងដើម្បីធ្វើការសិក្សា ។ ដុំធ្យូងជាច្រើនដែលគេរកឃើញក្នុងស្រទាប់លើ អនុញ្ញាតអោយគេចុះកាលកំណត់ដោយវិធីវិទ្យុសកម្ម(G 14):

- ស្រទាប់ទី ១ = 1200 BP (750 ក្រោយ គ.ស.)
- ស្រទាប់ទី ៣ = 4200 BP (2050 មុន គ.ស.)
- ស្រទាប់ទី ៤ = 6250 BP (4290 មុន គ.ស.)

## ១.៤ ស្ថានីយភ្នំក្បាលរមាស

នៅចន្លោះឆ្នាំ១៩៦៦និងឆ្នាំ១៩៦៩ លោក Carbonnel និង Dalibrias បានធ្វើការរុករកក្នុងរូងភ្នំដែលជាលំនៅរបស់មនុស្សបុព្វប្រវត្តិសាស្ត្រនៅភ្នំក្បាលរមាសក្នុងខែត្រកំពត ។ នៅទីនោះលោកទាំងពីរបានរកឃើញនូវ គ្រឿងថានឆ្នាំងដែលមានអាយុ ៣៤២០ឆ្នាំមុន គ.ស.(11) ។

# ២. ជីវភាពក្នុងសម័យបុព្វប្រវត្តិសាស្ត្រ

## ២.១ ពូជមនុស្ស

ការសិក្សាឆ្អឹងលលាដ៍ដែលលោកAymonier បានរកឃើញនៅសំរោងសែននៅឆ្នាំ១៩០១បានបង្ហាញអោយយើងឃើញថា មនុស្សដែលរស់នៅ នៅសម័យសំរោងសែន គឺពិតជាបុព្វបុរសរបស់ជនជាតិខ្មែរសព្វថ្ងៃ ។ ឯការសិក្សាពីបំណែកឆ្អឹងផ្សេងៗ អោយយើងដឹងថាមនុស្សនៅសម័យនោះ ជាមនុស្សមានមាឌមធ្យមតែមាំហើយមានចិញ្ចើមលយទៀតផង ។

## ២.២ ភូមិស្រុក-របស់ប្រើប្រាស់

នៅយុគថ្មរំលីង មនុស្សចូលចិត្តរស់នៅក្នុងរូងភ្នំ (ភ្នំក្បាលរមាស-ភ្នំទាកទ្រាំង) ឬលើខ្ពង់រាប (មនុស្សសម័យមេមត់) ។ ក្រោយមកទៀតទើបចេញមករស់នៅត្រង់វាលខាងជើងបឹងទន្លេសាប

(សំរោងសែន-អន្លង់ផ្តៅ)ឬទៅខាងជើងបន្តិចទៀត(ម្លូព្រៃ) ។ ខ្ទមពួកនេះធ្វើពីឈើហើយសង់ខ្ពស់ពីដី ដើម្បីជៀសវាងទឹកជំនន់និងសត្វសាហាវ ។ ឯឈើដែលគេយកទៅសង់ផ្ទះ គឺបានមកពីកាប់ដោយពូថៅថ្មធំៗ ។ នៅក្នុងស្ថានីយជាច្រើន គេបានរកឃើញគំនរសំណល់ផ្ទះបាយមានជាអាទិសំបកខ្យង ខ្ចៅ ឆ្អឹងសត្វ ឆ្អឹងត្រី អំបែងក្អមឆ្នាំង ។ ល ។ ឯប្រដាប់ប្រើប្រាស់វិញមាន ក្អម ចាន ឆ្នាំង ពូថៅថ្ម ប្រដាប់សំរាប់ដំស្បែកសត្វ ។

## ២.៣ សកម្មភាពនៃអ្នកស្រុក

មនុស្សចេះធ្វើស្រែវស្សារួចហើយក្នុងតំបន់បឹងទន្លេសាប រហូតដល់ម្លូព្រៃថែមទៀត ព្រោះគេបានរកឃើញកណ្តៀវជាច្រើន ខ្លះធ្វើពីឆ្អឹងសត្វ ខ្លះធ្វើពីលង្ហិន ។ សត្វដែលគេចិញ្ចឹមច្បាស់ជាមានគោ និងជ្រូកនេះហើយ ។ ក្រៅពីស្រូវមនុស្សត្រូវការសាច់សត្វដែលគេបានមកដោយការបរបាញ់ ព្រោះគេបានរកឃើងចុងព្រួញ (១ធ្វើពីដែក ច្រើនទៀតធ្វើពីឆ្អឹង)និងពីការនេសាទត្រី (ផ្លែសន្ទូចធ្វើពីឆ្អឹង និងលង្ហិន ) ។

ត្រល់ដែលគេបានរកឃើញ បង្ហាញថាមនុស្សសម័យនោះចេះត្បាញទៅហើយ ។ គេមិនដឹងច្បាស់ថា វត្ថុធាតុដើមដែលគេប្រើក្នុងមុខរបរនេះជាអ្វីទេ តែបើតាមប៉ាន់ស្មានមើលទៅ គឺកប្បាសហ្នឹងឯង ។

## ២.៤ ជំនឿ-ទំនៀមទំលាប់

គេមិនអាចស្គាល់ច្បាស់ពីជំនឿ និងទំនៀមទំលាប់របស់មនុស្សដើមទាំងនោះទេ ។ ចំពោះវិធីរំលាយសព បើតាមគេស្មានមើលទៅប្រហែលគេដាក់សពអោយអង្គុយចោងហោង ហើយគេបំពាក់គ្រឿងអលង្ការអោយ មានកងដៃនិងខ្សែកជាដើម ។

# គ. អរិយធម៌អូស្ត្រូអាស៊ី

ការសិក្សាពីជីវភាពក្នុងសម័យបុព្វប្រវត្តិខាងលើបានបង្ហាញអោយឃើញថាជីវភាពនេះមានលក្ខណៈជា "**អរិយធម៌ អូស្ត្រូអាស៊ី**" ។ តើអ្វីទៅដែលហៅថា "អរិយធម៌អូស្ត្រូអាស៊ី "ហើយអរិយធម៌នេះមានគោលសំខាន់អ្វីខ្លះ ?

ក្នុងកាលដ៏យូរលង់ មុនការមកដល់នៃជនជាតិចិន និងជនជាតិឥណ្ឌាអាស៊ីអាគ្នេយ៍បានស្គាល់នូវអរិយធម៌ពិសេសមួយបែប ។ តាមពិតអរិយធម៌នេះបានលាតសន្ធឹងលើអាស៊ីខាងត្បូង ចាប់ពីប្រទេស

ឥណ្ឌូរហូតដល់ Nouvelle-Guinée ដោយរាប់បញ្ចូលទាំងប្រទេសចិនខាងត្បូងផង(ចាប់ពីទន្លេយ៉ង់សេចុះក្រោម)។ ដោយហេតុតែអរិយធម៌ទាំងនោះមានលក្ខណៈដូចគ្នាច្រើន គេក៏អោយឈ្មោះហៅថា "**អរិយធម៌អាស៊ីខាងត្បូង**"(អូស្ត្រូអាស៊ី) ឬ "(អរិយធម៌ខ្យល់រដូវ)"(12)។ យ៉ាងណាមិញលោក A .M Hocart និង លោក P .Mus បានសង្កេតឃើញមានភាពដូចគ្នាក្នុងជំនឿជាមូលដ្ឋាននិងក្នុងពិធីសំខាន់ៗក្នុងភូមិភាគអាស៊ីខ្យល់រដូវទាំងមូល។ គេមិនទាន់ដឹងច្បាស់ថាអរិយធម៌នេះហូរចេញពីមជ្ឈមណ្ឌលណានៅឡើយទេ។ ចំពោះរឿងនេះ មានសម្មតិកម្មពីរយ៉ាង (13) :

- អ្នកខ្លះយល់ថាប្រហែលជាមានអំបូរមនុស្សមួយ ឬច្រើនដែលមានឫសគល់ នៅឥណ្ឌូចិន ឬនៅលើកោះ បានហូរចូលទៅក្នុងប្រទេសឥណ្ឌាមុនកាលមកដល់របស់ពួកអារ្យ។

- ខ្លះទៀតយល់ផ្ទុយទៅវិញថាពួកទ្រាវិឌឬពួកអារ្យដែលចូលលុកលុយប្រទេសឥណ្ឌាតាមទិសពាយព្យបានរុញច្រានអោយពួកអ្នកស្រុកដើមថយទៅខាងត្បូងឬទៅខាងកើត ហើយបានធ្វើដំណើរទៅកាន់ឥណ្ឌូចិន និងប្រជុំកោះ Insulinde ។

ទោះជាមានប្រភពមកពីណាក៏ដោយ យើងអាចបញ្ជាក់នូវគោលសំខាន់ៗនៃអរិយធម៌អូស្ត្រូអាស៊ី បានដូចតទៅ ៖

## ១. ក្នុងវិស័យសម្ភារៈ

- ចេះធ្វើស្រែវស្សា
- ចេះវិធីបញ្ចូលទឹកក្នុងស្រែ
- ចេះប្រើគោក្របី និង ធ្វើប្រដាប់សំរាប់ធ្វើស្រែខ្លះ
- ចេះស្លលោហធាតុ
- ស្ទាត់ជំនាញខាងនាវាចរណ៍ៈ អរិយធម៌នេះត្រូវគេផ្សព្វផ្សាយរហូតដល់កោះ Madagascar ហើយអ្នកខ្លះថា រហូតដល់ប្រជុំកោះជប៉ុនថែមទៀត ព្រោះទំនាក់ទំនងនេះ គេសំអាងទៅលើប្រដាប់ប្រដាសម័យបុព្វប្រវត្តិសាស្ត្រ លើភាសានិងរបាំប្រពៃណី។ គេយល់ថា ហេតុដែលនាំអោយអរិយធម៌នេះត្រូវបានផ្សព្វផ្សាយទៅឆ្ងាយដូច្នេះ ព្រោះតែមនុស្សជំនាន់នោះចេះទាញផលប្រយោជន៍ពីភាពឆ្លាស់គ្នានៃខ្យល់រដូវ។

## ២. ក្នុងវិស័យសង្គមកិច្ច

ក្នុងវិស័យនេះមានការទុកស្រីជាធំក្នុងគ្រួសារនិងក្នុងសង្គម( Matriarcat )និងការរាប់ញាតិតាមខ្សែស្រឡាយខាងម្តាយ( filiation en ligne maternelle ) ។

ចំពោះខ្មែរយើង គោលសំខាន់ខាងលើនេះ តែងបានបន្សល់នូវដាន ជាក់លាក់តាំងតែពីដើមរហូតមកដល់សព្វថ្ងៃ ។ យ៉ាងណាមិញ រឿងព្រេងដែលទាក់ទងនិងការបង្កើតបឋមវង្ស ហើយដែលអ្នកប្រវត្តិសាស្ត្រចិនបានកត់ត្រាទុក(ហ៊ុនទៀននិងនាងលីវយី)បានបង្ហាញថាអ្នកដឹកនាំសង្គមខ្មែរក្នុងសម័យដើមមានភេទជាស្រី ។

ឯសិលាចារឹកបានអោយពត៌មានថា នៅសម័យអង្គរស្រីមានអំណាចទុកដាក់ចែកចាយទ្រព្យសម្បត្តិគ្រួសារ តាមចំណង់ចិត្តរបស់ខ្លួនដោយមិនបាច់សំយោបល់ពីប្តីទេចំណែកប្តីវិញ បើចង់ធ្វើអំណោយត្រូវទទួលការយល់ព្រមពីប្រពន្ធជាមុន ឬបើពុំដូច្នោះទេ ទាល់តែបញ្ជាក់ថា ទ្រព្យនោះជាទ្រព្យផ្ទាល់របស់ខ្លួនជាប្តីឥតមានទាក់ទងនិងប្រពន្ធទេ ។ ម្យ៉ាងទៀតការចែកកេរមត៌កតែងធ្វើតាមខ្សែស្រឡាយខាងស្រីជាដរាប : ការផ្ទេរងារជាព្រាហ្មណ៍មិនត្រូវផ្ទេរពីឪពុកទៅកូនទេ តែត្រូវផ្ទេរពីឪពុកមាទៅកូនប្រុសរបស់ប្អូនស្រីឬក៏ពីឪពុកមាទៅកូនប្រុសរបស់កូនស្រីនៃប្អូនស្រីរបស់ខ្លួន ។ របបចែកកេរមត៌កដោយចាប់យកខ្សែស្រឡាយខាងម្តាយជាធំ (matrilinéarité) ត្រូវគេយកទៅអនុវត្តក្នុងការផ្ទេររាជសម្បត្តិទៀត : សិលាចារឹកប្រែរូប(៩៦១)បានអោយដឹងថា ព្រះបាទរាជេន្ទ្រវរ្ម័នទី ២មានព្រះបិតាព្រះនាម មហេន្ទ្រវរ័ន្មដែលមានដើមកំណើតនៅ ភវបុរ (ចេនឡាដីគោក)ឯព្រះមាតាព្រះនាមមហេន្ទ្រទេវីជាបងបង្កើតរបស់ព្រះបាទយសោវរ្ម័នទី១ជាក្សត្រខាងសោមវង្សដោយហេតុនេះហើយ ទើបទ្រង់អាចទទួលរាជសម្បត្តិ ពីព្រះបាទហសិវរ្ម័នទី៤ ? ជាក្សត្រសោមវង្សបាន (១១)។

គួរកត់សំគាល់ថាមានរឿងព្រេងខ្មែរជាច្រើនបាននិទានពីការប្រកួតប្រជែងរវាងស្រី និងប្រុសក្នុងវិស័យផ្សេងៗ មានការជីកស្រះ ពូនភ្នំ សង់ប្រាសាទជាដើម ហើយទោះបីរឿងទាំងនោះបានបញ្ជាក់ថាភេទស្រីមានជ័យជំនះលើប្រុសក៏ដោយ ក៏សព្វថ្ងៃនេះសង្គមខ្មែរបានវិវត្តមកដល់ដំណាក់ការមួយដែលភេទស្រី ត្រូវបាត់បង់ឧត្តមភាពរបស់ខ្លួនទៅលើភេទប្រុសទៅហើយ ។ ក៏ប៉ុន្តែសង្គមនេះនៅរក្សាដានខ្លះល្មមអោយយើងជឿបាននូវអត្ថិភាពរបស់ទស្សនៈទុកស្រីជាធំនៅឡើយ ។ យ៉ាងណាមិញ របស់ ឬមនុស្សដែលមានភាពឬមានតួនាទីជាធំចម្បងលើគេឯងទៀត ខ្មែរយើងនៅតែហៅថា មេ ដូចជាមេដៃមេជើង មេដំបូល  មេដែក មេទ័ព មេឃុំ មេស្រុក មេគយ មេការ ។ល។ ក្នុងការស្តីដណ្តឹងគូស្រករត្រូវប្រុសចូលទៅនិយាយសុំសេចក្តីយល់ព្រមពីខាងស្រី លុះដល់ពេលរៀបការក៏ខ្មែរយើងនិយមទៅធ្វើផ្ទះខាងស្រីទៀត ។ ហើយភស្តុតាងដែលជាក់ស្តែងជាងនេះទៅទៀត គឺពាក្យស្លោកខ្មែរមួយវគ្គដែលបានចែងថា “សូវស្លាប់បាកុំអោយស្លាប់មេ សូវលិចទូកកណ្តាលទន្លេកុំអោយភ្លើងឆេះផ្ទះ” ។

ដោយអាងទៅលើគោលធំមួយនៃអរិយធម៌ខ្មែរ គឺការទុកស្រីជាធំក្នុងគ្រួសារនិងក្នុងសង្គមនេះ ហើយទើបយើងយល់ថា **ខ្មែរ** ទំនងជាក្លាយមកពី **ក + មេ** ដូចមានការវិវត្តន៍ដូចតទៅនេះ ៖

**ក + មេ › កមេ › ក្មេ › ក្មេរិ › ខ្មេរិ › ខ្មែរ**

- ក្នុងភាសាខ្មែរ ព្យញ្ជនៈ "**ក** " ជាបុព្វបទមួយសំរាប់ធ្វើន័យរបស់ពាក្យណាមួយ អោយមានលក្ខណៈកាន់តែខ្លាំងក្លាឡើង

***ឧទាហរណ៍*** កកាយ (កាយញាប់ជាងធម្មតា)

កកូរ (កូញាប់ជាងធម្មតា)

កខិក (សោច ពួខិកៗ ញាប់ជាងធម្មតា)

- មេ សំគាល់ស្ត្រីជាម្តាយនៅក្នុងគ្រួសារឬស្ត្រីជាអ្នកដឹកនាំនៅក្នុងសង្គម ។

- ក្មេរិ បានន័យថា អ្នកគោរពមេ គឺអ្នកធ្វើអោយមេមានលក្ខណៈកាន់តែច្បាស់ឡើង ។ ពាក្យនេះមានប្រើនៅក្នុងសិលាចារឹកមុនសម័យអង្គរ ដូចជានៅសិលាចារឹកប្រាសាទជាន់ជុំជាដើម ។

- ខ្មេរិ ក្លាយមកពីក្មេរិទៀតគឺ ក ក្លាយមកជា ខ ។ ពាក្យនេះមានប្រើនៅសម័យអង្គរ ក្នុងសិលាចារឹកប្រាសាទបន្ទាយឆ្មារជាដើម គឺនៅពេលដែលខ្មែរយើងបានបង្កើតតួ ខ សំរាប់សរសេរពាក្យបាលីសំស្ក្រិត ។

- ខ្មេរិក្លាយមកពីខ្មែរនេះទៀត ដូចជាម៉ែដែលបានក្លាយមកពីមេដូច្នោះដែរ ។

ដើម្បីជាការប្រៀបធៀប គួរគប្បីជ្រាបថាជនជាតិឥណ្ឌានិងជនជាតិចិន ដែលធ្លាប់តែជះឥទ្ធិពលរបស់ខ្លួនមកលើជាតិខ្មែរនោះ គេមិននិយមទុកស្ត្រីជាធំដូចខ្មែរយើងទេ តែផ្ទុយទៅវិញគឺគេទុកប្រុសជាធាតុមានតម្លៃជាងស្រី ។

ចំពោះជនជាតិឥណ្ឌាគេដឹងថា តាំងតែពីព្រេងនាយមកស្រីមេម៉ាយពុំមានសិទ្ធិយកប្តីថ្មីទៀតឡើយៈ កាលណាប្តីស្លាប់ទៅស្រីឥណ្ឌាត្រូវនៅបំរើគ្រួសារប្តីតទៅទៀតឬមួយលោតទៅក្នុងភ្លើងស្លាប់តាមប្តីដើម្បីជៀសអោយផុតពីលំបាកវេទនាក្នុងការរស់នៅ(15) ។ ម៉្យាងទៀតពាក្យ **ប្តី** ដែលក្លាយមកពីពាក្យ **បតិ** (=ម្ចាស់)ក៏អាចបង្ហាញអោយឃើញថា ជនជាតិឥណ្ឌាមានទស្សនៈខុសឆ្ងាយពីខ្មែរណាស់ ។

ចំណែកឯក្នុងសង្គមចិនវិញ គេឃើញមានការគោរពបូជាដូនតា ។ ក្នុងគ្រួសារនីមួយៗ គឺប្តីជាអ្នកមានមុខងារសំខាន់ក្នុងការទទួលខុសត្រូវធ្វើយ៉ាងណាអោយការគោរពបូជា នេះអាចប្រព្រឹត្តទៅដោយគ្មានឧបសគ្គ ។ បើឪពុកស្លាប់ទៅ គឺកូនប្រុសច្បងនេះហើយដែលត្រូវទទួលតំណែងសំខាន់ខាងលើជាជំនួសឪពុក ឯកូនស្រីគ្មាននាទីអ្វីបន្តិចបន្តួចសោះឡើយក្នុងបន្ទុកនោះ ។ ហេតុនេះហើយបានជាជនជាតិចិន មិនអោយតម្លៃទៅកូនស្រីទេៈ តែកាលណារៀបការហើយ គេតែងបញ្ជូនអោយទៅនៅគ្រួសារខាងប្រុស ។ បើកាលណាប្តីស្លាប់ត្រូវនៅបំរើគ្រួសារខាងប្តីតទៅទៀត ។ តាមទំលាប់ចិន កូនស្រីបើមិនទាន់មានប្តីត្រូវស្តាប់បង្គាប់ឪពុក បើមានប្តីត្រូវស្តាប់បង្គាប់ប្តី ហើយបើផុតពីប្តីទៅត្រូវស្តាប់បង្គាប់កូនប្រុសច្បង(régle des trois soumissions) ។ គួរកត់សំគាល់ម្យ៉ាងទៀតថា ជនជាតិចិននិយមអោយតម្លៃទៅ

ញាតិខាងឪពុក ៖ ឧទាហរណ៍ ដូចជាជីដូជីតា ខាងឪពុកគេហៅថា **ជីដូនជីតាក្នុង** ឯជីដូនជីតាខាងម្ដាយ គេហៅថា **ជីដូនជីតាក្រៅ** (ក្នុង គឺក្នុងវង្សត្រកូលគេ ក្រៅ គឺក្រៅវង្សត្រកូលគេមិនសូវរាប់រកទេ) ។

## ៣. ក្នុងវិស័យជំនឿ

មនុស្សជាន់ដើមជឿថាមនុស្សស្លាប់ទៅមិនសូន្យទេ គឺមានព្រលឹងទៅចាប់ជាតិថ្មីទៀត ។ ពួកខ្មែរលើដែលរស់នៅលើខ្ពង់រាបសព្វថ្ងៃ ក៏នៅមានជំនឿបែបនេះដែរពួកនេះចែកព្រលឹងជាបីប្រភេទគឺ ព្រលឹងធំដែលចេញពីខ្លួនមនុស្ស៦ខែមុនពេលស្លាប់ ព្រលឹងតូចចេញទៅនៅពេលស្លាប់និងព្រលឹងខ្លះទៀតស្លាប់៦ខែហើយទើបព្រមចេញ(១៦) ។ ដល់កាលណាមនុស្សស្លាប់ទៅគេយកទៅកប់ ហើយគេយកគ្រឿងប្រដាប់ដែលបុគ្គលនោះធ្លាប់ប្រើយកទៅកប់ជាមួយដែរ ដើម្បីទុកអោយប្រើប្រាស់តទៅទៀត ។ ខ្មែរយើងសម័យឥឡូវ តែកាលណាមានមនុស្សស្លាប់គេតែងរៀបគ្រឿងបន្ទុងប្រគេនចំពោះព្រះសង្ឃ ដើម្បីបញ្ជូនអោយអ្នកស្លាប់នោះដែរ ។ បើតាមការស្រាវជ្រាវរបស់បុព្វប្រវត្តិវិទូ មនុស្សជាន់ដើមនិយមបញ្ចុះខ្មោចក្នុងក្រឡ ឬក្រោមថ្មដុល (dolmen ឬ menhir) ដោយដាក់អោយសពអង្គុយ ។ ទំលាប់នៅស្ថិតស្ថេរហូតមកដល់សព្វថ្ងៃ ៖ បើកាលណាមានវរជនស្លាប់ គេយកសពទៅដាក់ក្នុងកោដ្ឋ ដែលប្រហែលជាក្លាយមកពីក្រឡនោះហើយ ឯធាតុរបស់រាស្ត្រសាមញ្ញ ក៏គេយកទៅដាក់ក្នុងកោដ្ឋ ហើយបញ្ចុះក្នុងចេតិយដែរ ។

ផលវិបាកសំខាន់ដែលហូរចេញពីជំនឿដែលថាមនុស្សស្លាប់ទៅមិនសូន្យគឺជំនឿលើខ្មោចអារក្សអ្នកតានេះឯង ។ អ្នកតាជាព្រលឹងនៃជនដែលស្លាប់ទៅហើយតែនៅថែរក្សាមើលសុខទុក្ខដល់កូនចៅតទៅទៀត(បើជាស្រីគេហៅថាអ្នកដូន) ។ ខ្មែរយើងសព្វថ្ងៃនៅមានជំនឿលើអ្នកតាច្រើននៅឡើយ ជាពិសេសក្នុងចំណោមអ្នកស្រែចំការ ៖ ខុមអ្នកតា គេឃើញមានពាសពេញភូមិស្រុកហើយពិធីសែនឡើងអ្នកតាក៏គេប្រារព្ធធ្វើរៀងរាល់ឆ្នាំដែរ ។ ពួកខ្មែរលើក៏មានជំនឿដូចគ្នានេះដែរ ហើយគេហៅអ្នកតាថា "ព្រះ" ។ ដូច្នេះយើងឃើញថា ពួកអ្នកស្រុកអាយមានទំលាប់គោរពបូជាដូនតានេះស្រេចទៅហើយនៅមុនពេលឥណ្ឌាចូលមកដល់ ។ លុះលទ្ធិពុទ្ធសាសនានាំចូលមក ជំនឿដែលចាត់ទុកថាមនុស្សស្លាប់ទៅមិនសូន្យ ព្រោះមានវិញ្ញាណទៅកកើតជារូបថ្មីទៀតក៏មានលក្ខណៈប្រហាក់ប្រហែលនឹងជំនឿរបស់អ្នកស្រុកអាយ(ព្រលឹងហើយនិងវិញ្ញាណមិនដូចបេះបិទទេ)ហើយក៏បានពួកនេះទទួលយកទៅ ។ សព្វថ្ងៃនេះបុណ្យភ្ជុំបិណ្ឌគឺជាបុណ្យសំយោគរវាងជំនឿបែបពុទ្ធសាសនានិងជំនឿរបស់អ្នកស្រុកអាយ ។

មនុស្សជំនាន់ដើមមានជំនឿម្យ៉ាងទៀតថាកន្លែងសំរាប់គោរពបូជាគឺស្ថិតនៅលើកំពស់មានកំពូលភ្នំជាដើម ។ គឺជំនឿបែបនេះហើយដែលបង្កើតអោយមានទស្សនៈក្នុងការកសាងប្រាសាទភ្នំ៖ អេតណូ-

រិទូខ្លះដូចជាលោក Quarit Ches WaTes បានពន្យល់ថាប្រាសាទភ្នំជាតំណាងភ្នំ ឯលិង្គតម្កល់ក្នុងប្រាសាទភ្នំគឺជាតួអ្នកតានេះឯង ។

ជំនឿមួយទៀតរបស់អ្នកស្រុកដើមដែលគួរអោយកត់សំគាល់ដែរ គឺការគោរពទេព្ដាដី ព្រោះដីជាមូលដ្ឋានផ្ដល់នូវស្រូវអង្ករជាអាហារសំខាន់ ។ ជំនឿនេះ គេឃើញមានរំឭកឡើងវិញក្នុងពិធី "ច្រត់ព្រះនង្គ័ល "បើករដូវធ្វើស្រែចំការ ។

## ៤. ក្នុងវិស័យភាសា

គេឃើញមានប្រើភាសា ដែលគេអាចបង្កើតពាក្យថ្មីបានដោយប្រើបទដើម (pr -fixes) បទជ្រែក (infixes) និងបទចុង (suffixes) ។ ចំពោះខ្មែរយើងវិធីកម្លាយពាក្យដោយប្រើបទដើមនិងបទជ្រែកឃើញនៅស្ថិតស្ថេររហូតដល់សព្វថ្ងៃហើយប្រកបដោយក្បួនខ្នាតច្បាស់លាស់ណាស់ ។ ម្យ៉ាងទៀត ការសិក្សាស្រាវជ្រាវបានបង្ហាញអោយឃើញថាវិធីបែបនេះ ក៏មានប្រើពិតប្រាកដក្នុងភាសាមនដែល :

### ភ្លូងតាសាខ្មែរ

ព + យល់ > ពន្យល់

ប + ដើរ > បណ្ដើរ

គិត > គំនិត ( គ + ន + ិ ត )

កាយ > កំណាយ (ក + ណ + ា យ )

### ភ្លូងតាសាមន

គេត (វិល) > ប: គេត (បង្វិល )

គើ (ឆេះ ) > ពគើ (បញ្ឆេះ)

ក្លួន (ធ្វើការ) > កម្លួន (កិច្ចការ)

ក្លួត (លួច) > កម្លួត (ចោរ)

# ជំពូក ៤

# ការចាក់រឹសគល់នៃអរិយធម៌ឥណ្ឌានៅអាស៊ីអគ្នេយ៍

ភូមិភាគអាស៊ីអគ្នេយ៍ទាំងមូលលើកលែងតែប្រទេសវៀតណាមនិងប្រទេសហ្វីលីពីនចេញ សុទ្ធតែបានទទួលឥទ្ធិពលរបស់ឥណ្ឌាទាំងអស់ ។ តើជនជាតិនេះបានធ្វើដំណើរមកកាន់អាស៊ីអគ្នេយ៍តាំងពីពេលណា ហើយអ្វីទៅជាបុព្វហេតុនាំអោយគេមកកាន់ភូមិភាគនេះ ?

ខុសពីការមកដល់របស់ជនជាតិចិន ដែលគេមានឯកសារប្រវត្តិសាស្ត្រគ្រប់គ្រាន់និងដឹងកាលកំណត់ច្បាស់លាស់ ការមកដល់របស់ជនជាតិឥណ្ឌានៅចោទជាបញ្ហានៅឡើយ ។ គេគ្រាន់តែដឹងថាជនជាតិឥណ្ឌាបានមកកាន់អាស៊ីអគ្នេយ៍តាំងពីសម័យបុព្វប្រវត្តិសាស្ត្រម្ល៉េះ ព្រោះគេបានរកឃើញវត្ថុមកពីឥណ្ឌាដូចជាត្រាឆ្លាក់អក្សរសំស្ក្រឹត (អូកែវ Kuala Selinsing នៅម៉ាឡេស្យា) និងព្រះពុទ្ធរូប ( Sempaga នៅកោះ Célèbes )នៅត្រង់ស្ថានីយថ្មរំលីងតែម្តង ។ ឯឯកសារសរសេរមានអាយុចាស់ជាងគេគឺ សិលាចារឹកវ៉ូកាញ់ (ស.វ. ទី ២.៣នៃគ . ស .)។

## ក. បុព្វហេតុ

ចំពោះបុព្វហេតុនៃការមកដល់របស់ជនជាតិឥណ្ឌា អ្នកស្រាវជ្រាវបានបញ្ចេញសម្មតិកម្មច្រើនបែបយ៉ាងដែលមានជាអាទិដូចតទៅ :

១. នៅស.វ.ទី ៣មុនគ.ស.ព្រះបាទអសោកបានលើកទ័ពទៅវាយលុករដ្ឋកលិង្គនៅឆ្នេរសមុទ្រខាងកើតនៃប្រទេសឥណ្ឌា ជាហេតុនាំអោយអ្នកស្រុកភៀសខ្លួនចេញពីទីនេះ ប៉ុន្តែគេនៅតែឆ្ងល់ថាចុះហេតុអ្វីបានជាដល់ ៣សតវត្សក្រោយទើបឃើញមានផលជាក់ស្តែងកើតឡើង ។ ដូច្នេះគេយល់ថាកាលណោះប្រហែលជាមានអ្នកភៀសខ្លួនខ្លះមែន ហើយពួកនេះគ្រាន់តែជាអ្នកបើកផ្លូវអោយពួកក្រោយៗដែលមានចំនួនច្រើនជាងប៉ុណ្ណោះ ។

២. អ្នកខ្លះយល់ថាបុព្វហេតុ គឺបណ្តាលមកពីការលុកលុយរបស់ពួកកុសាននៅគ្រិស្តស.វ.ទី១ ដែលបានរុញច្រានអោយអ្នកស្រុករត់គេចចេញពីទីនោះ ។ សម្មតិកម្មនេះមើលទៅហាក់ដូចជាសមរម្យច្រើនតែនៅមិនទាន់មានភស្តុតាងជាក់លាក់នៅឡើយ ។

៣. អ្នកខ្លះទៀតយល់ថា មានអ្នកផ្សងព្រេងឥណ្ឌាក្នុងវណ្ណៈខ្ពស់ៗ បានមកស្វែងរកភោគទ្រព្យនៅភូមិភាគដែលសម្បូណ៌ដោយមាសនិងគ្រឿងទេស តែនេះក៏ជាសម្មតិកម្មដែលមិនទាន់មានអ្វីអាចបញ្ជាក់នៅឡើយដែរ ។

៤. អ្នកស្រាវជ្រាវភាគច្រើននិយមចាត់ទុកថា ការមកដល់របស់ជនជាតិឥណ្ឌាមានប្រភពមកពីជំនួញទៅវិញ ។

ទំនាក់ទំនងរវាងភិភពមេឌីទែរ៉ានេនិងបូព៌ា ប្រទេសបន្ទាប់ពីយុទ្ធការរបស់ព្រះបាទអាឡិចសង់មហារាជ ការបង្កើតចក្រភពរបស់ព្រះបាទអសោកនិងក្រោយមករបស់ព្រះបាទកនិស្ក កំណើតនៃចក្រភព Séleucide និងចក្រភពរ៉ូម៉ាំង ទាំងនេះជាហេតុជម្រុញអោយជំនួញគ្រឿងប្រណីតមានសន្ទុះយ៉ាងខ្លាំង ។ ម្យ៉ាងទៀតគេដឹងថា អាស៊ីអគ្នេយ៍ជាកន្លែងសម្បូណ៌ដោយគ្រឿងទាំងនោះ(គ្រឿងទេស ឈើក្រអូបនិងមាស) ដូចដែលឈ្មោះផ្សេងៗអាចបង្ហាញអោយឃើញស្រាប់ :

- តក្កោល ( ផ្សារលក់ក្រវាញ )
- កប៉ូរទ្វីប (កោះកប៉ូរ )
- នរិកេលទ្វីប (កោះដើមដូង)
- កនកបុរី (ក្រុងមាស)
- សុវណ្ណភូមិ (ដីមាស)
- សុវណ្ណទ្វីប (កោះមាស)

ប្រទេសឥណ្ឌាធ្លាប់តែទិញមាសពីភូមិភាគស៊ីបេរី (Sibérie) ប៉ុន្តែនៅមុនគ.ស.បន្តិច ការរំជើបរំជួលក្នុងចំណោមជនជាតិផ្សេងៗនៅអាស៊ីកណ្តាលធ្វើអោយផ្លូវទៅកាន់ភូមិភាគនោះដោយឆ្លងកាត់តាមបាក់ទ្រីយ៉ាន (Bactriane) ត្រូវកាត់ដាច់ធ្វើគមនាគមន៍តទៅទៀតមិនកើត ។ ដោយហេតុនោះហើយបានជានៅគ្រិស្តស.វ.ទី១ ឥណ្ឌាបានងាកទៅរកទិញមាសពីចក្រភពរ៉ូម៉ាំងវិញប៉ុន្តែមិនយូរប៉ុន្មានអធិរាជវេស្បាស្យាង( Vespasien-69-79 គ.ស.) ទ្រង់ចេញបញ្ញត្តិហាមឃាត់មិនអោយនាំមាសចេញ ។ អ្នកស្រាវជ្រាវខ្លះយល់ថា នេះហើយជាហេតុនាំអោយឥណ្ឌាបែរមកស្វែងរកមាសនៅភូមិភាគអាស៊ីអាគ្នេយ៍វិញ ។

ការធ្វើដំណើរដ៏វែងឆ្ងាយនេះ ត្រូវបានសំរួលដោយកត្តាបីគឺ :

១- ការចំរើនលូតលាស់ក្នុងផ្នែកនាវាចរណ៍របស់ឥណ្ឌា ដោយពេលនោះគេចេះធ្វើសំពៅធំ ៗ អាចផ្ទុកមនុស្សបានពី៦០០ទៅ ៧០០នាក់ ។ ម្យ៉ាងទៀតនៅពាក់កណ្តាលស. វ. ទី១នៃ គ. ស. អ្នកបើកបរសំពៅជាតិក្រិកគឺៈ លោក Hippalos បានរកឃើញនូវភាពឆ្លាស់គ្នានៃខ្យល់រដូវជាហេតុជំរុញអោយមានសន្ទុះយ៉ាងខ្លាំងក្នុងផ្នែកជំនួញតាមផ្លូវសមុទ្ររវាងប្រទេសឥណ្ឌានិងកំពង់ផែទាំងឡាយនៅតាមឆ្នេរសមុទ្រក្រហម ។

២- ការចំរើនលូតលាស់នៃព្រះពុទ្ធសាសនា ព្រោះសាសនានេះបានលប់ចោលនូវប្រព័ន្ធវណ្ណៈដែលជាហេតុនាំអោយពួកឥណ្ឌាឈប់ខ្លាចបាត់ភាពបរិសុទ្ធខាងជាតិសាសន៍របស់ខ្លួន ដោយធ្វើការទាក់ទងជាមួយបរទេស ។ រឿងរ៉ាវដែលជាប់ទាក់ទងនិងការធ្វើនាវាចរណ៍តាមសមុទ្រ ត្រូវបានពួកអ្នកនិពន្ធឥណ្ឌារៀបរាប់ក្នុងគម្ពីរជាតក ។

៣- ការរីកធំនៃផ្សារជំនួញចិន ក្រោយដែលជនជាតិនេះបានវាយលុកយកបានតំបន់ផ្សេងៗនៅខាងត្បូងទន្លេយ៉ង់សេ (17) ។

ចំពោះបុព្វហេតុទី៤ដែលទាក់ទងនិងការធ្វើជំនួញនេះ អ្នកខ្លះយល់ថាពួកឈ្មួញឥណ្ឌាដែលគ្រាន់តែបានមកតាំងគ្រឹះស្ថានជំនួញរបស់ខ្លួននៅលើឆ្នេរសមុទ្រ ឃើញថាមិនអាចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនិងយ៉ាងយូរជាមួយនិងអ្នកស្រុកអាយ និងពួកមេកោយដើម្បីផ្សព្វផ្សាយឥទ្ធិពលវប្បធម៌របស់ខ្លួនបានឡើយ ។ ដោយហេតុនេះហើយបានជាគេបានសង្កត់ទៅលើវត្តមាននៃពួកបញ្ញវន្តឥណ្ឌានិងការវិលត្រឡប់មកកាន់មាតុប្រទេសវិញនៃពួកអ្នកស្រុក ក្រោយពីបានស្នាក់នៅ នៅប្រទេសឥណ្ឌាអស់មួយរយៈពេល ។

## ខ. ឥណ្ឌាបានមកផ្សាយអរិយធម៌របៀបណា ?

ក្នុងរឿងនេះ លោក G. Ferrand បានធ្វើសម្មតិកម្មមួយសំរាប់កោះជ្វា តែអ្នកស្រាវជ្រាវយល់ថាអាចយកទៅអនុវត្តចំពោះប្រទេសផ្សេងៗនៅអាស៊ីអាគ្នេយ៍ទាំងមូលបាន ។ លោកសរសេរថា : "ពួកចំណូលថ្មី(ឥណ្ឌា)" បានមកទាក់ទងជាមួយពួកមេដឹកនាំហើយយកចិត្តពួកនេះដោយជំនួន ការព្យាបាលជម្ងឺ និងការផ្តល់អោយនូវយ័នគាថា ។ ដោយពុំទាន់មានអ្នកបកប្រែភាសាពួកឥណ្ឌាត្រូវតែខិតខំរៀនភាសារបស់ពួកអ្នកស្រុក ។ បន្ទាប់មកបានរៀបមង្គលការជាមួយកូនស្រីរបស់ពួកមេដឹកនាំ : គឺចាប់ពីពេលនេះហើយដែលពួកឥណ្ឌាមានលទ្ធភាពផ្សព្វផ្សាយអរិយធម៌របស់ខ្លួនដោយមានជោគជ័យ ព្រោះថាពួកស្រីស្រុកអាយនេះបើកាលណាជ្រួតជ្រាបដោយគំនិតនិងជំនឿរបស់ប្តីខ្លួនហើយ ហើយនិយាយ

ផ្សាយតទៅទៀតនោះច្បាស់ជាពួកអ្នកស្រុកជឿតាមភ្លាមមិនខាន ។ តែដើម្បីសម្តែងឬពន្យល់គំនិត និងជំនឿថ្មីនេះបាន គេត្រូវតែប្រើពាក្យពេចន៍របស់ឥណ្ឌាដោយខានមិនបានព្រោះក្នុងភាសារបស់គេពុំមានពាក្យណាអាចយកទៅប្រើក្នុងកិច្ចការបែបនោះបានឡើយ ។

ក្នុងដំណាក់កាលទីពីរ គឺបន្ទាប់ពីពួកឈ្មួញមក មានពួកបញ្ញាវន្តក្នុងវណ្ណៈខ្ពស់ទាំងពីរមកដល់ ។ ចំពោះរឿងនេះគេយល់ថា ពួកព្រាហ្មណ៍ខ្លះដែលមានឈ្មោះល្បីពូកែខាងមន្តអាគមដោយសារការអោយពត៌មានរបស់ពួកឈ្មួញច្បាស់ជាបានពួកមេដឹកនាំអោយអារាធនាមកដើម្បីជួយបង្កើនអំណាច និងលើកកិត្យានុភាពរបស់ខ្លួនថែមទៀត ។

រួចមកហើយ យើងបានឃើញថាព្រះពុទ្ធសាសនាមានមុខងារយ៉ាងសំខាន់ក្នុងជំនួញផ្លូវសមុទ្រ រវាងឥណ្ឌានិងអាស៊ីអាគ្នេយ៍ ហើយគេបានសង្កេតឃើញទៀតថា ក្នុងប្រទេសជាច្រើនវត្ថុជាសក្ខីភាពចាស់បំផុតនៃការផ្សាយអរិយធម៌ឥណ្ឌាគឺព្រះពុទ្ធរូប **ទីបង្ករ** ដែលអ្នកធ្វើដំណើរតាមសមុទ្រនិយមគោរពណាស់ ។ ដូច្នេះ ឃើញថាពុទ្ធសាសនាមាននាទីយ៉ាងសំខាន់ ព្រោះហាក់ដូចបានបើកផ្លូវនាំអោយឥណ្ឌាមកកាន់អាស៊ីអាគ្នេយ៍ ។ ក៏ប៉ុន្តែរាជាណាចក្រនានាដែលបានបង្កើតឡើងនៅភូមិភាគនេះ មិនយូរប៉ុន្មានក៏បានទទួលយកនូវទស្សនៈសិវនិយមនៃរាជាធិបតេយ្យ ដែលមានមូលដ្ឋានស្ថិតលើទំនាក់ទំនងរវាងព្រាហ្មណ៍និងក្សត្រិយនិងការគោរពបូជាលិង្គទេវរាជ ។

ការបង្កើតរាជាណាចក្រ ដោយផ្លាស់ប្តូរគ្រឹះស្ថានជំនួញអោយទៅជារដ្ឋបែបនេះអាចប្រព្រឹត្តទៅដោយវិធី ២ យ៉ាង :

១- ឬមួយមានឥណ្ឌាណាម្នាក់តាំងខ្លួនជាមេដឹកនាំរបស់អ្នកស្រុកអាយដែលបានទទួលឥទ្ធិពលឥណ្ឌាច្រើនឬតិច ។

២- ឬមួយមានមេដឹកនាំអ្នកស្រុកចង់ពង្រឹងអំណាចរបស់ខ្លួន ដោយទទួលយកទស្សនៈរបស់បរទេស ។

ករណីទាំងពីរនេះអាចកើតឡើងបានដូចគ្នា ។ ប៉ុន្តែក្នុងករណីទី១ បើទោះជារាជវង្សមានសញ្ជាតិជាឥណ្ឌាសុទ្ធសាធ តាំងពីដើមមកក៏មិនអាចមានលក្ខណៈនេះវែងឆ្ងាយបានទេ ព្រោះគេពុំអាចចៀសវាងបាននូវការយកគ្នាជាប្តីប្រពន្ធរវាងឥណ្ឌានិងអ្នកស្រុកបានឡើយ ។

រឿង **ព្រះថោង នាងនាគ** ឬរឿង **ហ៊ុនទៀន-លីវយី** អាចបញ្ជាក់យើងពីចំនុចនេះបាន ។ ប៉ុន្តែចំពោះករណីទី ២ គឺការលើកពួកមេដឹងនាំអ្នកស្រុកអោយឡើងឋានៈ ជាក្សត្រិដោយពិធីវ្រាត្យស្តោមនោះគេយល់ថាមានញឹកញាប់ជាង ។

## គ. ឥណ្ឌាបានចេញពីតំបន់ណាខ្លះ ?

រឿងនេះពិបាកបញ្ជាក់ ព្រោះក្រៅពីអត្ថបទ ៣សរសេរជាភាសាទមិឡហើយដែលមានចុះកាល កំណត់ថ្មីៗនេះ គេឃើញមានតែឯកសារជាសំស្ក្រឹតដែលជាភាសាគេប្រើទូទៅនៅប្រទេសឥណ្ឌា ។ បើគេពិនិត្យឯកសារឥណ្ឌាដែលទាក់ទងនឹងការធ្វើនាវាចរណ៍ កំណត់ហេតុរបស់អ្នកធ្វើដំណើរចិនឈ្មោះទីកន្លែង អក្សរបុរាណ បុរាណវត្ថុ គេនឹងឃើញថា ពិតមែនហើយថាប្រទេសឥណ្ឌាខាងត្បូងជាពិសេស តំបន់ Kanchi (Conjeveram ) បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្សាយអរិយធម៌ឥណ្ឌានៅអាស៊ីអាគ្នេយ៍ តែតំបន់ផ្សេងៗទៀតនៃប្រទេសឥណ្ឌា (ខ្ពង់រាបទក្សិណ វាលទំនាបទន្លេគង្គា និងឥណ្ឌាភាគពាយព្យ)សុទ្ធតែបានចូលរួមចំណែកតិចឬច្រើនក្នុងព្រឹត្តិការណ៍ខាងលើទាំងអស់ ។

## ឃ. ឥណ្ឌាបានចេញដំណើរពីកន្លែងណា ?

ឯកសារផ្សេងៗមានជាអាទិកំណត់ហេតុរបស់អ្នកភូមិសាស្ត្រ (Ptolémée) និងរបស់អ្នកដំណើរ អឺរុប និងចិន បានចែងពីកំពង់ផែសមុទ្រធំៗដែលជាកន្លែងចេញដំណើររបស់ជនជាតិឥណ្ឌាមកកាន់អាស៊ីអគ្នេយ៍ :

ក - លើឆ្នេរសមុទ្រខាងកើតមានកំពង់ផែ តាម្រលិព្តិ ( តាម្លុក) កមរៈបោឌុកេ ។

ខ - លើឆ្នេរសមុទ្រខាងលិចមានកំពង់ផែ ករុគច្ឆ(ប្រូច)សូប៉ារកៈ និង មុនីរិ ។

ក្នុងការធ្វើដំណើរឆ្ពោះមកកាន់អាស៊ីអគ្នេយ៍នេះ ពួកឥណ្ឌាអាចប្រកាន់យកផ្លូវពីរ : ចំពោះពួកណាដែលធ្វើដំណើរទៅកាន់កោះនានានោះ ការប្រើប្រាស់ផ្លូវសមុទ្រជាការជៀសវាងពុំបានប៉ុន្តែចំពោះពួកណាដែលធ្វើដំណើរទៅកាន់ដីគោក ការចាំបាច់តម្រូវអោយគេប្រើផ្លូវទឹកផងផ្លូវគោកផង ។ ពិតមែនហើយថាដីសណ្ដរនៅឥណ្ឌូចិនដែលពោរពេញទៅដោយដើមចាកនោះគឺជាឧបសគ្គមួយ ប៉ុន្តែឧបសគ្គខាងភូមិសាស្ត្រនេះមានលក្ខណៈមិនសូវកាចសាហាវដូចពួកចោរសមុទ្រទេ ហើយគឺការដែលមានពួកចោរសមុទ្រនៅកកកុញក្នុងច្រកសមុទ្រនិងក្រោយមកទៀត ការអនុវត្តនយោបាយផ្តាច់ការខាងផ្លូវជំនួញរបស់រាជាណាចក្រប៉ាលេមបាងនេះហើយដែលផ្តល់អោយផ្លូវគោកនូវសារសំខាន់យ៉ាងធំដែលមានបុរាណវត្ថុជាភស្តុតាង ។

ក្រៅពីកំពង់ផែធំៗ ដូចបានរៀបរាប់មកហើយគួរគប្បីរាប់បញ្ចូលក្នុង "កន្លែងចេញដំណើរ " ដែរនៅមជ្ឈមណ្ឌលវប្បធម៌ខ្លះនៅលើជ្រោយមលយូដូចជា Takna Pa (តក្កោល) និងកេដៈ (kedah ) ដែលមានមុខងារជាតំណាក់បន្លាស់ (relais) ។ គឺនៅត្រង់កន្លែងទាំងពីរនេះហើយដែលពួកឥណ្ឌាបានដាក់ទំនិញចុះ រួចដឹកឆ្លងកាត់ឬដីក្រាតាមផ្លូវគោកយកទៅដាក់សំពៅនៅឆ្នេរម្ខាងទៀតដើម្បីធ្វើដំណើរទៅ

កាន់ឈូងសមុទ្រសៀមនិងសមុទ្រចិន ។ គេធ្វើដូច្នេះ គឺដើម្បីចៀសវាងនូវការធ្វើដំណើរដ៏វែងឆ្ងាយ ដោយកុងព័ទ្ធតាមច្រកសមុទ្រដែលនៅខាងត្បូង ។

## ខ. តើសង្គមអ្នកស្រុកអាយទទួលឥទ្ធិពលឥណ្ឌាដល់កំរិតណា ?

ក្នុងដំណោះស្រាយបញ្ហាដ៏សំខាន់នេះគេឃើញមានទស្សនៈ២ផ្ទុយគ្នាស្រឡះ ។ ចំពោះពួកសង្គមវិទូដែលនិយមអោយតម្លៃច្រើនទៅលើធាតុពូជសាសន៍និងប្រពៃណីយល់ថា អរិយធម៌របស់អ្នកស្រុកអាយបានរក្សាលក្ខណៈផ្ទាល់របស់ខ្លួននៅពេលដែលបានទើបប្រទះនឹងអរិយធម៌ឥណ្ឌា ។ ចំពោះពួកអ្នកសិក្សាពីអរិយធម៌ឥណ្ឌា ( indiauistes) ដែលផ្អែកទៅលើបុរាណវត្ថុនិងសិលាចារឹកយល់ថា អរិយធម៌នៅអាស៊ីអគ្នេយ៍គ្រាន់តែជាមែកធាងនៃអរិយធម៌ឥណ្ឌាប៉ុណ្ណោះ ។

ដូច្នេះឃើញថាចំពោះពួកសង្គមវិទូអរិយធម៌បុរាណទាំងនោះជាលទ្ធផលនៃការវិវត្តន៍របស់អរិយធម៌អ្នកស្រុកអាយដោយបានប៉ះទង្គិចជាមួយអរិយធម៌ឥណ្ឌា : ធាតុសំខាន់គឺអ្វីដែលអ្នកស្រុកមានហើយ ( génic local) ហើយដែលមានប្រតិកម្មនឹងធាតុឥណ្ឌា (stimulus) ។ ឯពួកអ្នកសិក្សាអំពីអរិយធម៌ឥណ្ឌាអះអាងផ្ទុយទៅវិញថា អរិយធម៌បុរាណទាំងនោះជាការសំរបសំរួលនៃអរិយធម៌ឥណ្ឌាតាមប្រទេសនីមួយៗទៅវិញ គឺចាត់ទុកថាអរិយធម៌ឥណ្ឌាជាឈើតែមួយដើមដែលបានផ្តល់ផ្លែផ្កាទៅ តាមលក្ខណៈដីផ្សេងៗ ។

ជំពូក ៥

# ប្រភពនៃប្រវត្តិសាស្ត្រខ្មែរ

ប្រវត្តិសាស្ត្រខ្មែរមានប្រភពសំខាន់ពីរ គឺប្រភពជាតិមួយនិងប្រភពបរទេសមួយ ។

## ក. ប្រភពជាតិ

### ១. សិលាចារឹកនិងបុរាណវត្ថុ

ពិតមែនហើយសិលាចារឹកនិងបុរាណវត្ថុជាប្រភពយ៉ាងសំខាន់ តែការសិក្សាស្រាវជ្រាវក្នុងវិស័យទាំងពីរនេះគឺជនជាតិអឺរុបទេដែលបានផ្ដើមធ្វើឡើងមុនគេ ។ ដូច្នេះ គួរគប្បីយើងសិក្សាពីបុព្វហេតុដែលជម្រុញអោយជនជាតិនេះចូលធ្វើការទាក់ទងនឹងខ្មែរហើយចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវប្បធម៌អរិយធម៌យើងរហូតដល់ខំធ្វើការសិក្សាស្រាវជ្រាវយ៉ាងសកម្ម ។

### ១.១. បុព្វហេតុដែលបណ្ដាលអោយពួកអឺរុបមកកាន់អាស៊ីអាគ្នេយ៍

គេនៅចាំបានថា នៅគ្រិស្ត ស.វ.ទី១៥មនុស្សនៅបស្ចិមប្រទេសមានសេចក្ដីត្រូវការគ្រឿងទេសយ៉ាងខ្លាំង ។ ជនជាតិអឺរុបបានស្គាល់គ្រឿងបរិភោគប្រភេទនេះជាលើកដំបូងដោយសារពួកទាហានដែលទៅច្បាំងដណ្ដើមយកផ្នូរពីព្រះយេស៊ូពីកណ្ដាប់ដៃពួកអារ៉ាប់នៅប៉ាលេស្ទីន ហើយនាំយកទៅស្រុកវិញដើម្បីអោយក្រុមគ្រួសារខ្លួនបានស្គាល់រសជាតិផង ។ លុះចេះប្រើប្រាស់គ្រឿងបរិភោគថ្មីនេះហើយសេចក្ដីត្រូវការរបស់គេក៏ចេះតែកើនឡើងជាលំដាប់ ។ ពួកឈ្មួញអារ៉ាប់និងប៉ែរ្សបានទៅនាំគ្រឿងទេសទាំងនោះ ពីអាស៊ីអាគ្នេយ៍ហើយយកទៅលក់នៅអឺរុបដោយបានទទួលប្រាក់ចំណេញជាច្រើន ។ នៅអឺរុបពួកឈ្មួញនៅក្រុងYenise និង Génés បានទទួលទិញគ្រឿងទេសអស់នោះដើម្បីយកទៅលក់អោយប្រទេសឯទៀតៗដោយបានចំណេញច្រើន ជាហេតុនាំអោយតម្លៃទំនិញកាន់តែកើនឡើងៗ ។ ដោយ

ហេតុនោះជនជាតិព័រទុយក័លក៏មានគំនិតឃើញថា ប្រសិនបើគេអាចធ្វើដំណើរទៅដល់កន្លែងផលិតគ្រឿងទេសតែម្តង នោះគេនឹងទិញបានដោយតម្លៃថោកជាទីបំផុត ។

ក្រោយពីធ្វើការរុករកអស់រយៈពេលច្រើនឆ្នាំ(ពី១៤៣៤ដល់១៤៩៨)កងនាវាព័រទុយក័លក៏បានធ្វើដំណើរទៅដល់អាស៊ីអាគ្នេយ៍ ។ ចម្បាំងក៏កើតមានឡើងរវាងពួកព័រទុយក័លនិងពួកអារ៉ាបជាអ្នកបានមកដល់ទីនោះមុន ។ នៅទីបំផុតពួកព័រទុយក័លបានទទួលជោគជ័យដោយវាយយកបានក្រុងម៉ាឡាក់កាជាផ្សារអន្តរជាតិមួយយ៉ាងធំនៅឆ្នាំ១៥១១ ។ ឃើញដូច្នោះហើយពួកជនជាតិអឺរុបឯទៀតៗក៏បញ្ជូនកងនាវាមកភូមិភាគអាស៊ីអាគ្នេយ៍ជាបន្តបន្ទាប់គ្នាគឺ ហុល្លង់ អេស្ប៉ាញ អង់គ្លេស បារាំង ហើយជម្លោះក៏កើតមានឡើងជានិច្ចជាកាលក្នុងវិស័យជំនួញ ។

## ១.២. ទំនាក់ទំនងខ្មែរ -អឺរុប

ក្រោយពីបានពង្រឹងជំហររបស់ខ្លួននៅជ្រោយមលយូ ហើយពួកព័រទុយក័លគឺជាជនជាតិអឺរុបដំបូងដែលបានចូលមកទាក់ទងជាមួយខ្មែរក្នុងរជ្ជកាលរបស់ព្រះបាទអង្គចន្ទ(១៥៥៥) ។ ក្នុងចំណោមអ្នកដែលចូលមកក្នុងប្រទេសខ្មែរ មានខ្លះជាអ្នកផ្សាយសាសនាហើយខ្លះទៀតជាអ្នកផ្សងព្រេង ។ គឺពួកចុងក្រោយនេះហើយដែលបានទៅនៅបំរើស្តេចខ្មែរ បានធ្វើដំណើរទស្សនាប្រទេសខ្មែរ ហើយបានកត់ត្រាទុកនូវហេតុការណ៍ដែលខ្លួនបានឃើញ ។ គឺកំណត់ទាំងនោះហើយដែលអ្នកប្រវត្តិសាស្ត្របានយកទៅប្រើជាឯកសារសំរាប់ឆ្លុះមើលសង្គមខ្មែរក្នុងសម័យក្រោយអង្គរ ជាពិសេសក្នុងស.វ.១៦ នេះឯង ។ បន្ទាប់ពីជនជាតិព័រទុយក័លមក មានពួកអេស្ប៉ាញ ហើយចុងក្រោយបង្អស់គឺពួកបារាំងដែលបានចូលមកតាំងអាណាព្យាបាលភាពរបស់គេលើប្រទេសខ្មែរ ។

## ១.៣. ការសិក្សាស្រាវជ្រាវពីអរិយធម៌ខ្មែរដោយជនជាតិអឺរុប ។

បើពិនិត្យទៅឃើញថា គឺការរុករករបស់ពួកអាណានិគមនិយមស្បែកស នេះហើយជាវិសគល់នៃការសិក្សាស្រាវជ្រាវយ៉ាងពេញទំហឹងពីអាស៊ីអាគ្នេយ៍ ជាទូទៅនិងពីប្រទេសខ្មែរជាពិសេស ។ បុព្វហេតុធំៗគឺថាពួកនេះមានការចាំបាច់ក្នុងផ្នែកនយោបាយផង មានចំណង់ចង់ចេះដឹងរបស់ដែលនៅក្រៅប្រ ទេសផង ហើយចង់បានចំណេះថ្មីខាងផ្នែកមនុស្សសាស្ត្រដែលកំពុងតែរីកចំរើនឡើងនៅទ្វីបអឺរុបផង(18) ។

សូមបញ្ជាក់ថាការសិក្សាស្រាវជ្រាវពីអាស៊ីអាគ្នេយ៍បានធ្វើឡើងក្រោយការសិក្សាស្រាវជ្រាវពីប្រទេសចិននិងឥណ្ឌា ដូច្នេះហើយបានជាមានទំនោរចង់ចាត់ទុកថាអាស៊ីអាគ្នេយ៍គ្រាន់តែជាអាណាខេត្ត

របស់ប្រទេសធំៗទាំងពីរខាងលើតែប៉ុណ្ណោះ ។ តែការសិក្សាស្រាវជ្រាវជាបន្ទាប់មកបានបង្ហាញអោយឃើញនូវភាពប្លែកនិងភាពរុងរឿងនៃអរិយធម៌នៅអាស៊ីអគ្នេយ៍ ។

នៅឆ្នាំ១៨៦១លោក Henri Mouhot ធម្មជាតិវិទូបារាំងម្នាក់បានមកដល់អង្គរ ។ ក្នុងកំណត់ហេតុរបស់លោក លោកបានស្ងើចសរសើរយ៉ាងខ្លាំងចំពោះប្រាសាទខ្មែរ ។ នៅឆ្នាំ១៨៦៣បូព៌ាវិទូ (orientaliste) ជាតិអាល្លឺម៉ង់ A Bastian បានរកឃើញថាអក្សរនិងសាសនាខ្មែរនៅសម័យអង្គរមានដើមកំណើតមកពីឥណ្ឌា ។ បីឆ្នាំក្រោយទៀត(១៨៦៦)លោកJ. Thomson ជាតិអេកូស បានថតរូបអង្គរជាលើកដំបូង ហើយបានបកស្រាយអំពីនិមិត្តរូបនិយមលោកធាតុនៃអង្គរវត្តតាមបែបហិណ្ឌូនិយម ។

សូមបញ្ជាក់ថាការរកឃើញប្រាង្គប្រាសាទ ដ៏ល្បីឈ្មោះរបស់ខ្មែរបានធ្វើស្របពេលជាមួយនិងការវាយ យកដែនដីកូសាំងស៊ីន និងកិច្ចចរចាខាងផ្លូវទូតរវាងបារាំងនិងសៀម ដែលព្រមព្រៀងអោយបារាំងតាំងអាណាព្យាបាលភាពរបស់ខ្លួនលើប្រទេសខ្មែរ(19) ។ ក្រោយពីបានមកគ្រប់គ្រងប្រទេសខ្មែរហើយរាជការបារាំងបានចាត់តាំងគណៈបេសកកម្មរុករកជាច្រើនក្នុងបំណងធ្វើអោយគេស្គាល់អរិយធម៌ខ្មែរ ។ គណៈបេសកកម្មសំខាន់បំផុតបានតាំងឡើងនៅឆ្នាំ ១៨៦៦-១៨៦៧ ហើយបានដឹកនាំដោយលោកវរៈនាវីទោ Doudart de Lagrée ។ នាយទាហានរូបនេះបានទៅធ្វើការរុករកនៅតំបន់អង្គរ តែលោកពុំទាន់បានទាញយកផលប្រយោជន៍អ្វីពីកិច្ចការរបស់លោកនៅឡើយ ព្រោះលោកបានទទួលមរណភាពក្នុងអាណាខេត្តយូនណាន ។ សហការីរបស់លោកជាពិសេស លោកអនុនាវីឯក francis Garnier បានយកឯកសារទាំងឡាយ ដែលលោកបានប្រមែប្រមូលនោះ យកទៅធ្វើប្រភេទវិភាគរួចបោះពុម្ពផ្សាយ ដោយដាក់ចំណងជើងថា « Voyage d´exploration en Indochinc » នៅឆ្នាំ១៨៧៣ ។ សហការីម្នាក់ទៀតគឺលោក Louis Delaporte បាននាំយកទៅប្រទេសបារាំងនូវរូបចម្លាក់និងរូបស្មិតជាច្រើន ហើយបានរៀបចំតាំងពិពណ៌មួយនៅក្រុងប៉ារីស ស្ដីពីស្នាដៃខ្មែរដែលបានធ្វើអោយសាធារណជនចាប់អារម្មណ៍យ៉ាងខ្លាំង ។ ពីឆ្នាំ១៨៧៥ដល់ឆ្នាំ១៨៧៧ លោកបណ្ឌិត Jules Harmand ក្រោយពីបានធ្វើការរុករកនៅប្រទេសខ្មែរនិងប្រទេសលាវហើយ បានផ្ញើទៅជូនលោក Hendrik Kern បូព៌ាវិទូជាតិហូល្លង់ម្នាក់នូវផ្ទាំងអក្សរផ្តិត (estampages) នៃសិលាចារឹក ។ អ្នកប្រាជ្ញរូបនេះបានអានដាច់អត្ថបទសំស្ក្រឹត ហើយបានបោះពុម្ពផ្សាយនៅឆ្នាំ១៨៧៩ ។ ចំណែកឯលោក Etienne Aymonier ដំបូងជាអធិការកិច្ចការអ្នកស្រុកអាយ បន្ទាប់មកជា Résident Supérieur នៃប្រទេសកម្ពុជាបានប្រមូលបានអក្សរផ្តិតចំនួន ៣៤០ផ្ទាំង ខ្លះជាភាសាសំស្ក្រឹត ខ្លះជាភាសាខ្មែរបុរាណ(១៨៨២-១៨៨៥) ហើយបានអានដាច់ខ្លួនលោកអស់មួយភាគធំ ។ លោកAuguste Barth អ្នកផ្តើមធ្វើការសិក្សាស្រាវជ្រាវពីប្រទេសឥណ្ឌានិងសហការីម្នាក់ លោក Abel Bergaigne បានបកប្រែនិងបោះពុម្ពផ្សាយអត្ថបទសិលាចារឹកជាភាសាសំស្ក្រឹតរបស់ខ្មែរនិងរបស់ចាម ដែលផ្តល់ជូនលោកនូវកាលបរិច្ឆេទនិងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ នៅ

ឆ្នាំ ១៨៨៣ លោក Jean Moura ជា Résident Supérieur បានបោះពុម្ពផ្សាយប្រវត្តិសាស្ត្រ ទី១ នៃប្រទេសខ្មែរ « Le Royaume du Combodge » ។ លោក Etienne Aymonier ដែលបានបន្តតំណែងពីលោក Moura បានបោះពុម្ពសៀវភៅ « Le Cambodge » នៅឆ្នាំ១៩០០ ។

ការសិក្សាស្រាវជ្រាវនៅចុងបូព៌ាប្រទេសមានទំហំកាន់តែធំឡើង សេចក្ដីត្រូវការនិងសេចក្ដីចំរើនលូតលាស់ក្នុងវិស័យនេះ តម្រូវអោយមានការបង្កើត អង្គការអចិន្ត្រៃយ៍ ព្រោះឯកជនម្នាក់ៗ ឬសមាគមអ្នកប្រាជ្ញខ្លះ (ដូច Societé des Etudes Indochinoises ដែលតាំងនៅព្រៃនគរពីឆ្នាំ១៨៦៥) មិនអាចបំពេញកិច្ចការដ៏ធំធេងខាងលើអោយបានពេញលេញឡើយ ។ គឺនៅក្នុងក្របខណ្ឌនេះហើយដែល " ភាសាបារាំងនៅចុងបូព៌ាប្រទេស "( Ecolefrançaise d´Extreme-Orient) ត្រូវបង្កើតឡើងដោយឥណ្ឌាវិទូសំខាន់ៗដូចជាលោក Barth Bréal និង Bergaigne ។ ដំបូងឡើងអង្គការនេះមានទីតាំងនៅព្រៃនគរ (១៨៩៨) ក្រោយមកត្រូវបានលើកយកទៅតាំងនៅក្រុងហាណូយដោយលោក Paul Doumer ដែលបានបង្កើតនៅទីនោះនូវក្រសួងភូមិសាស្ត្រនិងក្រសួងភូគព្ភសាស្ត្រ(១៨៩៩)ថែមទៀត ។ ក្រោយមកទៀតអង្គការនេះត្រូវទទួលមើលការខុសត្រូវលើសារមន្ទីរនិងប្រាង្គប្រាសាទទាំងឡាយនៅឥណ្ឌូចិនទៀត ។

ជាមួយនឹងការបង្កើត « សាលាបារាំងនៅចុងបូព៌ាប្រទេស » លោក Georges Coedès និងលោក Louis Finot បានធ្វើអោយការសិក្សាស្រាវជ្រាវផ្នែកសិលាចារឹកខ្មែរចេះតែមានការចំរើនលូតលាស់ជានិច្ច : មានសិលាចារឹកជាង១០០០អត្ថបទត្រូវបានបកប្រែនិងបោះពុម្ពផ្សាយ ។

ចាប់ពីឆ្នាំ១៩០០ហើយដើម្បីជាផលប្រយោជន៍ «សាលាបារាំងនៅចុងបូព៌ាប្រទេស » លោក Lunet de Lajonquière បានធ្វើបញ្ជីសារពើភ័ណ្ឌនៃប្រាង្គប្រាសាទខ្មែរ ។ ក្នុងពេលជាមួយគ្នានោះលោក Henri Parmentier ត្រូវបានទទួលបន្ទុកមើលខុសត្រូវកិច្ចការខាងបុរាណវត្ថុវិទ្យា ។ នៅឆ្នាំ១៩០៧ ខេត្របាត់ដំបងនិងសៀមរាបត្រូវបានសៀមសងមកអោយខ្មែរវិញ ។ ភ្លាមនោះ ការអភិរក្សអង្គរ (Conservation d´Ankor) ក៏បានបង្កើតឡើងហើយដឹកនាំដោយលោក J .Commaille និងបន្ទាប់មកដោយលោក Henri Marchal ។ កិច្ចការដំបូងដែលគេចាប់ធ្វើគឺ កាប់ឆ្ការព្រៃដែលដុះព័ទ្ធជុំជិតប្រាសាទនិងស្រង់ឈ្មោះប្រាសាទជាបន្តពីកិច្ចការរបស់លោក Lunet de La jonquière : មានប្រាសាទទាំងអស់ជាង១០០០ត្រូវបានគេរកឃើញ ។ លោក Georges Groslier បានបង្កើតសារមន្ទីរមួយនៅភ្នំពេញនៅឆ្នាំ១៩១៨ ។ ការថតរូបប្រាសាទសំខាន់ៗខ្លះបានធ្វើឡើងនៅប្រាសាទបាយ័ន (១៩០៨) ដោយលោក Dufour និង Carpeaux រួចនៅអង្គរវត្តនិងបន្ទាយឆ្មារ ។

ក្នុងដំណាក់កាលទី១នេះ កិច្ចការសំខាន់របស់សិលាចារឹកវិទូគឺរកអោយឃើញឈ្មោះនិងកាលកំណត់កសាងប្រាសាទ ។ នៅឆ្នាំ១៩៣៥ លោក Philippe Stern បានទៅបំពេញបេសកកម្មនៅតំបន់អង្គរនិងភ្នំគូលែន ហើយលោកបានអោយគេកាប់ឆ្ការព្រៃដុះព័ទ្ធប្រាសាទនៅទីនោះ ។ នៅឆ្នាំ១៩៣៩ គឺជា

លើកដំបូងហើយដែលលោកស្រី Gilberte de Coral Rémusat បានបង្ហាញអោយឃើញជាស្ថាពរនូវតំណកាលកំណត់និងវិវត្តន៍រចនាបថនៃប្រាសាទទាំងឡាយរបស់ខ្មែរ ។

ក្នុងពេលជាមួយគ្នានោះ សេចក្ដីចំរើនលូតលាស់ក្នុងវិស័យរុះរើប្រាសាទដើម្បីសាងសង់ឡើងវិញ (anastylose) ដែលសំរេចឡើងដោយក្រសួងបុរាណវត្ថុវិទ្យាហុល្លង់នៅកោះជ្វាបានធ្វើអោយក្រុមអភិរក្សអង្គរចាប់អារម្មណ៍យ៉ាងខ្លាំង ។ លោក Georges Trouvé អភិរក្សអង្គរពីឆ្នាំ១៩៣១ដល់ឆ្នាំ១៩៣៥ បានយកបច្ចេកទេសថ្មីនោះមកអនុវត្តនៅប្រទេសខ្មែរ ។ លោកបានរកឃើញវត្ថុបុរាណជាច្រើន និងបានយល់ច្បាស់ពីសារសំខាន់នៃការបង្ហូរទឹកបញ្ចូលស្រែរបស់ជនជាតិខ្មែរក្នុងសម័យបុរាណ ។ លោក Maurice Glaize ដែលបានបន្តតំណែងពីលោកពីឆ្នាំ១៩៣៧ ដល់ឆ្នាំ១៩៤៥ បានយកបច្ចេកទេសថ្មី នោះអនុវត្តជាបន្តទៅទៀតចំពោះប្រាសាទសំខាន់ៗរបស់ខ្មែរ ដែលអាចនៅគង់វង់បានដោយសារតែរូបលោក ។ នៅទីបំផុតកិច្ចការស្រាវជ្រាវ និងថែរក្សាបានប្រព្រឹត្តជាទូទៅក្នុងប្រទេសខ្មែរ ដូចជានៅប្រាសាទអាស្រមមហាឫសី នៅភ្នំជីសូរនិងនៅភ្នំបាយ៉ង់ជាដើម ។

ចាប់ពីឆ្នាំ ១៩០៨ដល់ឆ្នាំ ១៩១១ វត្ថុនិងស្ថានីយខ្លះក្នុងចំណោមវត្ថុនិងស្ថានីយខ្មែរដែលមានចំណាស់ជាងគេបានរកឃើញដោយ លោក Hemriparmentier និងលោក ឧត្តមសេនីយ de Beylié ។ លោក Louis Mallenet អភិរក្សសារមន្ទីព្រៃនគរ (បង្កើតនៅឆ្នាំ១៩២៨) បានធ្វើការរុករកយ៉ាងសកម្មហើយរកឃើញស្ថានីយអូកែវក្នុងដែនដីកម្ពុជាក្រោមសព្វថ្ងៃ ។

## ២. រាជពង្សាវតារ

ពាក្យរាជពង្សាវតារនេះកើតមកពីការផ្សំនៃពាក្យៈ

រាជ + ពង្ស + អវតារ > រាជពង្សាវតារ

រាជៈ អ្វីដែលជារបស់ស្ដេចផែនដី

ពង្ស< វង្ស : ក្រសែ

អវតារៈ ដំណើរឆ្លងចុះ - ដំណើរប្រែប្រួល

ដូច្នេះ រាជពង្សាវតារ គឺឯកសារដែលអធិប្បាយអំពីដំណើរប្រែប្រួលរបស់វង្សស្ដេចផែនដីក្នុងអតីតកាល ។

បើតាមឯកសារចិន រាជពង្សាវតារប្រហែលមានតាំងពីសម័យអាណាចក្រភ្នំម្លេះ ព្រោះអ្នកធ្វើដំណើរចិន បានកត់ទុកថាមានកន្លែងទុកបណ្ណសារ ។ មួយផ្នែកទៀតសិលាចារឹករបស់ព្រះបាទសូរ្យវរ្ម័នទី១ នៅប្រាសាទព្រះវិហារ បាននិយាយពីត្រកូលមន្ត្រីដែលមានមុខងារថែរក្សារាជពង្សាវតារ ។ តែគួរ

អោយស្តាយ ! រាជពង្សាវតារនៅសម័យនោះមិនស្ថិតស្ថេររហូតដល់សព្វថ្ងៃនេះទេ នេះប្រហែលជាត្រូវអន្តរាយទៅដោយធាតុអាកាសឬដោយការបំផ្លិចបំផ្លាញរបស់ខ្មាំងសត្រូវដែលចូលមកឈ្លានពានទឹកដី ឬមួយដោយប្រការណាមួយដែលគេមិនអាចដឹងបាន ។

## ២.១. រាជពង្សាវតារដែលគង់វង់រហូតមកដល់សព្វថ្ងៃ

រាជពង្សាវតារជាឯកសារដែលអ្នកប្រវត្តិសាស្ត្រប្រើសំរាប់ចងក្រងប្រវត្តិសាស្ត្រខ្មែរជាបន្តពីឯកសារសិលាចារឹកគឺចាប់ពីស.វទី១៤មក ។ រាជពង្សាវតារទាំងនេះបានរៀបចំឡើងនៅស.វ.ទី១៩ ដោយពឹងផ្អែកទៅលើការទន្ទេញចាំមាត់ខ្លះ និងលើអត្ថបទបុរាណខ្លះ ដែលពីដើមតំកល់ទុកនៅក្រុងឧដុង្គ ។ ដោយអាស្រ័យហេតុទាំងនេះហើយទើបមានភាពខុសប្លែកគ្នាក្នុងផ្នែកព្រឹត្តិការណ៍ផងនិងក្នុងផ្នែកកាលកំណត់ផងពីច្បាប់មួយទៅច្បាប់មួយទៀត ។

## ២.២. រាជពង្សាវតាររបស់ឧកញ៉ាវង្សាសារពេជ នង

ឧកញ៉ាវង្សាសារពេជនង ជារាជគ្រូរបស់ព្រះបាទហរិរក្សរាមាអង្គដួង ។ លោកបានចងក្រងរាជពង្សាតារមួយច្បាប់ពីឆ្នាំ១៨១៣ដល់ឆ្នាំ១៨១៨ ។ ស្នាដៃរបស់លោកត្រូវបានប្រែជាភាសាយួននៅឆ្នាំ១៨៣៥និងជាភាសាសៀមនៅឆ្នាំ ១៨៥៥ រួចមកត្រូវបានចម្លងជាតួអក្សរឡាតាំងដោយលោកឧកញ៉ា-កុលដីម៉ុងតេរ៉ូសំរាប់លោក Douldart de Lagrée ។ លោកFrancis Garnier បានអោយប្រែស្នាដៃនេះជាភាសាបារាំងនៅឆ្នាំ១៨៦៥-១៨៦៦ហើយបានចុះផ្សាយក្នុងទស្សនាវដ្តី Journal Nsiatique (១៨៧៣) តែដោយហេតុមានកង្វះព្រឹត្តិការណ៍នៅស្រុកខ្មែរពីឆ្នាំ១៧៣៩ដល់ឆ្នាំ១៧៨៥ទើបលោកយកឯកសារ Gia dinh Thong Chi មកបង្គ្រប់ ។ ឯកសារនេះប្រហែលបានសរសេរនៅឆ្នាំ១៨១០ដោយលោកទ្រិញហ្វាយឌឹកក្នុងរជ្ជកាលរបស់ស្តេចមិញម៉ាង ហើយត្រូវបានបកប្រែជាបារាំងដោយលោកអនុនាវីឯក Gabriel Aubaret (20) ។

## ២.៣. រាជពង្សាវតារឯទៀតៗ

រាជពង្សាវតារឯទៀតៗដែលស្ថិតស្ថេររហូតដល់សព្វថ្ងៃគឺៈ នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ :

- **ព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតី** របស់លោកឧកញ៉ាវាំងជួន ។
- **ព្រះរាជពង្សាវតារនគរខ្មែរ** (ចម្លងតាមក្បួនវត្តកោកកាកតាំងពីឆ្នាំ១៩៤៤) ។
- **ព្រះរាជពង្សាវតារខត្តិយារមហារាជ** (ចម្លងតាមក្បួនវត្តសិតបូរតាំងពីឆ្នាំ១៩៤១) ។ ក្បួនវត្ត

សិតបូរនេះជាសេចក្ដីចម្លងពីរាជពង្សាវតាររបស់ឧកញ៉ាវង្សាសារពេជនងផ្នែកចាប់ពីរជ្ជកាលព្រះបាទនិព្វានបទតទៅ ឯផ្នែករឿងព្រេងចងក្រងឡើងដោយព្រះអង្គម្ចាស់ **នពរត្ន** ។ នៅបណ្ណាល័យអតីតវាំងៈ

- **ពង្សាវតារប្រទេសកម្ពុជា** ស្លឹករិតមានចំនួន៣២ខ្សែ ចាប់ពីស្ដេចចាម៦អង្គ និងវង្សស្ដេចខ្មែរ ចាប់ពីព្រះថោងកុមែរាជវហូតដល់ព្រះរាមាធិបតី ព្រះស្រីសុយោពណ៌គ. ស. ១៦៣៧ចារដោយព្រះគ្រូសិរីវង្សាមេគណ **មាស់ ស៊ុក** វត្តទឹកវិលសង្កាត់កោះខែល ស្រុកស្អាង(កណ្ដាល)ពីឆ្នាំ១៩៤១ ។

- **ពង្សាវតារប្រទេសកម្ពុជា** ស្លឹករិតមានចំនួន១២ខ្សែ ពីស្ដេចចាម ៥អង្គ និងស្ដេចខ្មែរចាប់ពីព្រះបាទអាទិច្ចវង្សមុន គ.ស.៣១២ឆ្នាំ ដល់ព្រះអង្គទងគំរប់ ២ដងគ. ស. ១៧៥១ ។

## ខ. ប្រភពបរទេស

### ១. ប្រភពចិន

ប្រទេសចិនបានចាប់អារម្មណ៍មកលើភូមិភាគនៅអាស៊ីអគ្នេយ៍នេះជាយូរណាស់មកហើយហើយបានលើកទ័ពវាយយកប្រទេសតុងកឹង ដើម្បីត្រួតត្រាផ្ទាល់តាំងពីឆ្នាំ១១១មុនគ. ស. ដល់ឆ្នាំ៩៣៩នៃគ. ស. ទៀតផង (21) ។

នៅពាក់កណ្ដាលសតវត្សទី៣នៃគ. ស. បេសកជនចិនពីរនាក់គឺលោកកាំងថៃ(kangTai ) និងលោកឈូយីង(Tchou Ying) បានមកស្នាក់នៅក្នុងអាណាចក្រភ្នំអស់មួយរយៈពេល ។ លុះត្រឡប់ទៅវិញលោកកាំងថៃបានបោះពុម្ពផ្សាយនូវកំណត់រឿងរ៉ាវដែលទាក់ទងនឹងការធ្វើដំណើរដ៏វែងឆ្ងាយរបស់លោក ។ តមកព្រះរាជាគ្រប់គ្រងលើអាណាចក្រភ្នំតែងបានទាក់ទងយ៉ាងខ្ជាប់ខ្ជួនជាមួយនឹងប្រទេសចិន ។ ដោយហេតុនេះហើយ ទើបមានគណៈបេសកកម្មខាងទូត ខាងជំនួញ និងខាងវប្បធម៌ត្រូវបានប្ដូរគ្នា ទៅវិញទៅមកជាញឹកញាប់ ហើយហេតុការណ៍ទាំងនោះបានអ្នកប្រវត្តិសាស្ត្រចិនកត់ទុកយ៉ាងហ្មត់ចត់ ។

ក្រៅពីឯកសារដែលមានលក្ខណៈផ្លូវការខាងលើនេះ នៅមានកំណត់ហេតុស្ដីពីរឿងរ៉ាវទាក់ទងនិងបូជនីយេសក៏ចិនកាន់ពុទ្ធសាសនា ។ ពុទ្ធសាសនិកទាំងនោះ ភាគច្រើនជាអ្នកចេះដឹងហើយមានជំនឿយ៉ាងមុះមុតលើពុទ្ធសាសនា បានធ្វើដំណើរទៅប្រទេសឥណ្ឌាដើម្បីទស្សនាកន្លែង ពិសិដ្ឋៗខ្លះនិងដើម្បីបង្កើនចំណេះខាងសាសនាថែមទៀតផង ។ ការធ្វើដំណើរទាំងនោះបានពង្រាយពី ស. វ. ទី៣ដល់ ស. វ. ទី១១នៃគ. ស. ។ ពុទ្ធសាសនិកទាំងនោះបានធ្វើដំណើរតាមសមុទ្រ ហើយបានចូលឈប់សំចតក្នុងរដ្ឋដែលបានទទួលឥទ្ធិពលឥណ្ឌា ។ ស្នាដៃដែលមាននិយាយពីស្រុកខ្មែរ គឺកំណត់ហេតុលោកស្យុនសាង(Hiuan tsang) និងលោកយីស៊ីង(Yi-tsing) (ស. វ. ទី ៧) ។

ក្នុងចំណោមឯកសារចិនទាំងឡាយ ឯកសារដែលសំខាន់ជាងគេគឺ កំណត់ហេតុរបស់លោក ជីវតាក្វាន់(Tcheou ta -Kouan) មានចំណងជើងថា "**កំណត់ហេតុស្ដីពីទំនៀមទំលាប់នៃប្រទេសចេនឡា**" (Tchen La fong t'ou Ki) ។ កំណត់ហេតុនេះបាននិយាយរៀបរាប់ពីប្រទេសខ្មែរនៅចុងសម័យអង្គរគឺ បានធ្វើការពណ៌នាពីរាជធានី ពីជីវភាព ការរស់នៅ ទំនៀមទំលាប់របស់អ្នកស្រុកនិងពីស្ថាប័ននានាក្នុងសម័យនោះ ។ ស្នាដៃរបស់លោកជីវតាក្វាន់បានប្រែជាភាសាបារាំងពីរលើក :លើកទី១ដោយលោក Abel Rémusat នៅឆ្នាំ១៨១៩ និងលើកទី២ដោយលោក Paul Pelliot នៅឆ្នាំ១៩០២ ។ គឺសេចក្ដីបកប្រែចុងក្រោយនេះហើយដែលអ្នកសិក្សាស្រាវជ្រាវច្រើនប្រើជាឯកសារក្នុងការស្រាវជ្រាវអំពីអរិយធម៌ខ្មែរ ។ គួរបន្ថែមដែរថា លោកលី **ធាម តេង** ជាសមាជិកសមាគមអ្នកនិពន្ធខ្មែរ ដែលបានទៅទស្សនាប្រទេសចិននៅឆ្នាំ១៩៦២បានចម្លងយកឯកសាររបស់លោកជីវតាហ្វាន់ជាភាសាចិនហើយយកមកប្រែជាភាសាខ្មែរបោះពុម្ពផ្សាយនៅឆ្នាំ១៩៧១ ។

## ២. ប្រភពបរទេសឯទៀត

ក្រៅពីឯកសារជាតិនិងឯកសារចិនដែលជាឯកសារមូលដ្ឋាននៅមានឯកសារបន្ទាប់បន្សំខ្លះទៀតដែលចងក្រងឡើងដោយជនជាតិក្រិច ឥណ្ឌា អារ៉ាប់ ព័រទុយក័ល អេស្ប៉ាញ យួន សៀម និងលាវ ។

នៅស.វ.ទី ២នៃគ.ស. អ្នកភូមិសាស្ត្រក្រិចឈ្មោះ Ptolémée បានសរសេរសៀវភៅភូមិសាស្ត្រដែលមានវគ្គមួយនិយាយពីភូមិភាគអាស៊ីអគ្នេយ៍ជីគោកនិងដីកោះ ។ អ្នកស្វែងរកមាសអោយឈ្មោះភូមិភាគនេះថា **សុវណ្ណភូមិ** (សំគាល់ដីគោក) និង**សុវណ្ណទ្វីប** (សំគាល់ដីកោះ) គឺត្រូវនឹងពាក្យ La Chrysé និង La Chersonèse របស់ជនជាតិក្រិច ។

មានផ្នែកខ្លះក្នុងគម្ពីរត្រៃបិដកក៏បានសរសេរពីកំពង់ផែសំខាន់ៗទាក់ទងនឹងការធ្វើជំនួញរវាងប្រទេសឥណ្ឌានិងភូមិភាគអាស៊ីអគ្នេយ៍ដែរ ។ អត្ថបទទាំងនោះគឺរឿង **ជាតក និង និទ្ទេស** ។

ឯកសារព័រទុយក័ល និង អេស្ប៉ាញ ក៏បានរួមចំណែកខ្លះក្នុងការចងក្រងប្រវត្តិសាស្ត្រខ្មែរដែរ ។ នៅឆ្នាំ១៩៥៤ក្នុងឱកាសបើកសម័យប្រជុំសមាជអន្តរជាតិលើកទី២៣នៃបូព៌ាវិទូនៅក្រុង Cambridge លោក Boxer បានយកឯកសារមួយរបស់លោក Diogo do Couto ដែលនិយាយពីក្រុងអង្គរនៅស.វ.ទី១៦ទៅលាតត្រដាង(22) ។ លោក Bernata Philippe Groslier បច្ចុប្បន្នអភិរក្សអង្គរបានសរសេរសៀវភៅមួយមានចំនងជើងថា " Angkor et le Cambodge Au 16 Siécle " ដោយពឹងផ្អែកទៅលើឯកសារព័រ-ទុយក័ល និងអេស្ប៉ាញហើយបោះពុម្ពនៅប៉ារីសនៅឆ្នាំ១៩៥៨ ។

ចុងក្រោយបង្អស់ រាជពង្សាវតារសៀម លាវ និងយួនក៏អាចជួយបំភ្លឺប្រវត្តិសាស្ត្រខ្មែរដោយអន្លើខ្លះដែរ តែឯកសារទាំងនេះមានគុណវិបត្តិដូចរាជពង្សាវតារខ្មែរដែរ ។

# បញ្ជីឯកសារពិគ្រោះ


1 - Adhémard Leclére, l'Histoire du Cambodge, Geuthner, Paris 1914.

2 - Pierre Gourou, l´Asie, Paris, 1971.

3 - G . Olivier. les populations du Cambodge. Paris1956.

4 - B.P. Groslier Indochine, carrefour des arts, éditions Albin Michel, Paris,1961.

5 - Henri V. Valloi , les races humaines, PUF, Que Sais-je ? Paris1967.

6 - Maurice Glaize les monuments du groupe d´Angkor, Paris 1963.

7 - Revue France- Asie, n• spécial pour la civilisation khmère, 1954

8 - អំបូរខ្មែរ និងអាស៊ីអគ្នេយ៍- អត្ថបទចុះក្នុងសារពត៌មានប្រយោជន៍ខ្មែរពីលេខ១៥៧ថ្ងៃទី២៨ កញ្ញា១៩៧០ដល់លេខ១៥២ថ្ងៃ ៦តុលា ១៩៧០ ។

9 - J . Deniker . les races et les peuples de la terre , Paris , 1926.

10 - B.P . Groslier, Découvertes archéologiques récentes au Cambodge, dans kambuja n°16, juillet 1966.

11 - Monuments historiques et sites, dans Final Report Volume ll of Preparatory Conference on the restoration and animation of historical sites for the Purpose of establishing the ARCAFA Phnompenh,1973.

12- B.P. Groslier, Angkor, hommes et pierres, Arthaud, 1956.

13 - G . Coedès, les Etats hindouisés d´indochine et d´Inedonésie, Paris 1964

14 - មុខងារស្ត្រីនៅសម័យអង្គរ ដោយនិសិត្សមួយក្រុមនៃវិញ្ញាបនប័ត្រ ឧត្តមសិក្សាផ្នែកវប្បធម៌-អរិយធម៌ខ្មែរ-ភ្នំពេញ-១៩៧៣ ។

15- A . Bonifacio, Histoire classes terminales, Paris, 1966

16- Médecin- Colonel Lieurade, Généralités, sur les populations montagnard es du Sud indochinois, Bulletin de la Sociétè des Etudes indochinoises, Tome xxvi, 1951.

17- G. Coedès les peuples de la Péninsule indochinoise, Dunod , Paris ,1962

18- B.P. GRoslier, Indochine, éditions Nagel, Genève, 1966

19 - Henri Marchal, Angkor, Paris, 1955

20 - លោក ដួង សារិន - ប្រវត្តិសាស្ត្រកម្ពុជា - មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ ភ្នំពេញ គ.ស. ១៩៦២-១៩៦៣ ។

21 - P. Fabricius, Prolégoménès à l'histoire du Cambodge, dans France - Asie, novembre - décembre 1960.